**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

# សារណាបញ្ចប់ការសិក្សា

# ឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ នៅលើកំណើនសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ដាន់ ឆលីហៀង**

**មល កុឡាវិត្ត**

សាស្ត្រាចារ្យណែនាំ

លោក **ទួន ផល្លា**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **មល កុលឡាវិត្ត** និង **ដាន់ ឆលីហៀង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**ឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា**" យើងខ្ញុំសូមធ្វើការគោរពជូន និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដូចតទៅ៖

ជាបឋមយើងខ្ញុំសូមសំដែងនូវការដឹងគុណ និងការគោរពដ៏ខ្ពង់ខ្ពស់ចំពោះអ្នកមានគុណទាំងពីរ នូវគុណដ៏ធំធេងពីរគឺ ជាតិគុណ និងឧបការគុណ ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងអប់រំទូលមានប្រៀនប្រដៅដែលពិសេសនោះគឺ លោកទាំងពីបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត និងធនធានទំនុកបម្រុងការសិក្សាតាំងពី ថ្នាក់បឋម រហូតដល់ថ្នាក់បរិញ្ញាបត្រ ដែលជាថ្នាក់ឧត្តមសិក្សានេះ។

លោកគ្រូ **ទូន ផល្លា** ដែលបានជួយជ្រោមជ្រែង ដឹកនាំ និងផ្តល់ជាទស្សនៈល្អៗ ហើយបានកែតម្រូវរាល់កំហុសខុសឆ្គង ដែលមាននៅក្នុងសារណានេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតទទួលបានជោគជ័យ ទោះបីជាមានពេលវេលាស្តួចស្តើងយ៉ាងណាក៏ដោយ។

លោកគ្រូ **ជ្រឹង ហៃ** ដែលលោកបានខិតខំបង្រៀនវិធីសាស្ត្រស្រាវជ្រាវ និងជួយណែនាំអំពីរបៀបសរសេរសារណា។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ការចូលរួមចំណែកដល់ការសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមក ចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការ ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងបុគ្គលិកដែលកំពុងបម្រើការនៅសាកលវិទ្យាល័យទាំងអស់ ព្រមទាំងមិត្តរួមថ្នាក់ដែលបានសិក្សាជាមួយគ្នាកន្លងមក។

# អារម្ភកថា

សារណា គឺជាការប្រមូលផ្តុំនៅចំណេះដឹង ដែលនិស្សិតបានចំណាយពេលអស់រយៈពេល៤ឆ្នាំមកនេះ និងជាសមទ្ធផលចុងក្រោយនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលជាការស្រាវជ្រាវកម្រិតបឋម ក្នុងរយៈពេលកំណត់មួយ។ ជាក់ស្តែងសារណាមួយនេះជា លទ្ធផលចុងក្រោយ និងជាចំណេះដឹងដែលបានសិក្សាអស់រយៈពេល ៤ ឆ្នាំនៃថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍។

ការស្រាវជ្រាវលើប្រធានបទ "**ឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា**" គឺមានគោលបំណងក្នុងការពង្រីកចំណេះដឹងលើ ស្ថានភាពតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ មកលើកំណើនសេដ្ឋកិច្ចកម្ពុជា ថាមានផលវិជ្ជមាន ឬអវិជ្ជមាន។ ការស្រាវជ្រាវនេះនឹងផ្តល់នូវចំណេះដឹងលើផ្នែកទ្រឹស្តីសេដ្ឋកិច្ច ដែលទាក់ទងទៅនឹងកំណើន និងការវិនិយោគពីបរទេស ជាពិសេសនោះគឺគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះក៏ធ្វើការវិភាគលើទិន្នន័យ៥ឆ្នាំចុងក្រោយ ដែលអាចបង្ហាញថា តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញបានផ្តល់ផលវិជ្ជមាន ឬអវិជ្ជមានទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា។

ជាចុងក្រោយយើងខ្ញុំទាំងពីរូបសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកបម្រើការក្នុងសកលវិទ្យាល័យទាំងមូល និងមិត្តអ្នកអានទាំងអស់ ដែលមានចំណាប់អារម្មណ៍ និងបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការអានកិច្ចការស្រាវជ្រាវរបស់ពួកយើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចការស្រាវជ្រាវនេះ ពិតជាមានកង្វះខាត និងកំហុសខុសឆ្គងណាមួយជៀសពុំផុត ដែលកើតឡើងដោយសារចំណេះដឹង និងបទពិសោធន៍នៅមានកម្រឹត ព្រមទាំងពេលវេលាមានកំណត់។ ដូច្នេះហើយ យើងខ្ញុំទាំងពីរសូមខន្តីអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយ និងស្វាគមន៍រាល់មតិរិះគន់ដើម្បីស្ថាបនាពីសំណាក់លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ លោក លោកស្រី និងមិត្តនិស្សិត ដើម្បីកែលម្អសៀវភៅនេះឲ្យប្រសើរជាងមុន។ ម្យ៉ាងវិញទៀត យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាឯកសារមួយនេះពិតជាផ្តល់ផលប្រយោជន៍ និងខ្លឹមសារសំខាន់ៗដែលជាចំណេះដឹងសម្រាប់ការសិក្សាស្រាវជ្រាវបន្តបន្ទាប់។

# មាតិកា

បញ្ជីអក្សរកាត់ .................... iv
បញ្ជីតារាង .................... vi
បញ្ជីក្រាហ្វិក .................... vii
បញ្ជីឧបសម្ព័ន្ធ .................... viii

## សេចក្ដីផ្ដើម

១. លំនាំបញ្ហាការស្រាវជ្រាវ .................... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ .................... ២
៣. គោលបំណងនៃការស្រាវជ្រាវ .................... ២
៤. សារៈសំខាន់នៃការស្រាវជ្រាវ .................... ២
៥. ដែនកំណត់នៃការស្រាវជ្រាវ .................... ២
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ .................... ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .................... ៣

## ជំពូកទី ១ ៖ រំលឹកទ្រឹស្ដី

១.១ ទស្សនៈទាននៃតំបន់សេដ្ឋកិច្ចពិសេស (SEZ) និងកំណើនសេដ្ឋកិច្ច .................... ៥
១.១.១ និយមន័យតំបន់សេដ្ឋកិច្ចពិសេស .................... ៥
១.១.២ និយមន័យកំណើនសេដ្ឋកិច្ច .................... ៥
១.១.៣ ផលិតផលជាតិសរុប (GDP) .................... ៦
១.១.៣.១ ការកើនឡើងនូវតម្រូវការសរុប (Aggregate demand) .................... ៦
១.១.៣.២ ការកើនឡើងនូវផ្គត់ផ្គង់សរុប (Aggregate supply) .................... ៨
១.២ ទ្រឹស្ដីនៃកំណើនសេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ចពិសេស .................... ៩
១.២.១ ទ្រឹស្ដី Neo-classical Theory: Solow Model .................... ៩
១.២.២ ទ្រឹស្ដី Endogenous Growth Theory .................... ១០
១.២.៣ ទ្រឹស្ដី Agglomeration Economies Approach .................... ១២

## ជំពូកទី ២៖ ស្ថានភាពទូទៅនៃសេដ្ឋកិច្ចកម្ពុជា

២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា .................... ១៤
២.១.១ កំណើនសេដ្ឋកិច្ច .................... ១៤

២.១.២ និកម្មភាព ...................................................................................... ១៥
២.១.៣ ភាពក្រីក្រ ...................................................................................... ១៧
២.១.៤ ពាណិជ្ជកម្មអន្តជាតិ ...................................................................................... ១៨
២.១.៤.១ ការនាំចេញ ...................................................................................... ១៩
២.១.៤.២ ការនាំចូល ...................................................................................... ២០
២.១.៤.៣ ការអនុគ្រោះពន្ធពីបរទេស ...................................................................................... ២១
២.១.៥ ការវិនិយោគផ្ទាល់ពីបរទេស ...................................................................................... ២២
២.២ ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា ...................................................................................... ២៣
២.២.១ លក្ខណៈទូទៅនៃសេដ្ឋកិច្ចកម្ពុជា ...................................................................................... ២៣
២.២.២ វិស័យឧស្សាហកម្ម ...................................................................................... ២៤
២.២.៣ វិស័យកសិកម្ម ...................................................................................... ២៥
២.២.៤ វិស័យសេវាកម្ម ...................................................................................... ២៨

**ជំពូកទី ៣៖ ដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ**

៣.១ ប្រវត្តិសង្ខេបនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ...................................................................................... ៣០
៣.២ គោលបំណងក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ...................................................................................... ៣១
៣.៣ លក្ខខ័ណ្ឌ និងនីតិវិធី ...................................................................................... ៣២
៣.៣.១ លក្ខខ័ណ្ឌក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ...................................................................................... ៣២
៣.៣.២ នីតិវិធីក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ...................................................................................... ៣៣
៣.៣.៣ នីតិវិធីចុះឈ្មោះគម្រោងវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ...................................................................................... ៣៤
៣.៤ គោលនយោបាយរដ្ឋាភិបាល ...................................................................................... ៣៥
៣.៤.១ ការលើកទឹកចិត្តផ្នែកសារពើពន្ធ ...................................................................................... ៣៥
៣.៤.១.១ ពន្ធលើប្រាក់ចំណេញ ...................................................................................... ៣៥
៣.៤.១.២ ពន្ធគយ និងអាករដ៏ទៃទៀត ...................................................................................... ៣៥
៣.៤.១.៣ អាករលើតំលៃបន្ថែម ...................................................................................... ៣៦
៣.៥ អត្ថប្រយោជន៍ដែលប្រទេសកម្ពុជាទទួលបានពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ...................................................................................... ៣៧
៣.៥.១ លំហូរការវិនិយោគផ្ទាល់ពីបរទេស ...................................................................................... ៣៧
៣.៥.២ ការបង្កើតការងារ ...................................................................................... ៣៨

៣.៥.២.១ ការបង្កើតការងារដោយផ្ទាល់ ........ ៣៨
៣.៥.២.២ ការបង្កើតការងារដោយប្រយោល ........ ៣៩
៣.៥.២.៣ ការបង្កើតការងារសម្រាប់ស្ត្រី ........ ៣៩
៣.៥.៣ ការអភិវឌ្ឍន៍ជំនាញ ........ ៣៩
៣.៥.៤ លំហូនៃបច្ចេកវិទ្យា ........ ៤០

## ជំពូកទី ៤ ៖ ការវិភាគទិន្នន័យ

៤.១ ការកំណត់អថេរ និងគំរូវិភាគ ........ ៤២
៤.២ ការបង្ហាញទិន្នន័យ ........ ៤២
៤.៣ ការបកស្រាយទិន្នន័យ ........ ៤៣
៤.៣.១ ការវិភាគលើលទ្ធផល ........ ៤៣
៤.៣.២ លទ្ធផលស្រាវជ្រាវ ........ ៤៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៤៥
២. ការផ្តល់អនុសាសន៍ ........ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank |
| | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFTA | ASEAN Free Trade Area |
| | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| CDC | The Council for the Development of Cambodia |
| | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| EBA | Everything But Arms |
| | ទំនិញគ្រប់យ៉ាងលើកលែងតែសភាវុធ |
| FDI | Foreign Direct Investment |
| | វិនិយោគផ្ទាល់ពីបរទេស |
| GDP | Gross Domestic Product |
| | ផលិតផលក្នុងស្រុកសរុប |
| GNI | Gross National Income |
| | ប្រាកចំណូលជាតិសរុប |
| GSP | Generalized System of Preference |
| | ប្រព័ន្ធអនុគ្រោះពន្ធទូទៅ |
| ILO | International Labor Organization |
| | អង្គការពលកម្មពិភពលោក |
| NPRS | National Poverty Reduction Strategy |
| | យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ |
| PPP | Purchasing Power Parity |
| | អំណាចនៃការទិញ |
| PPSEZ | Phnom Penh Special Economic Zone |
| | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ |
| QIP | Qualified Investment Project |
| | គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |

| | |
|---|---|
| SEZ | Special Economic Zone<br>តំបន់សេដ្ឋកិច្ចពិសេស |
| UNCTAD | United Nations Conference on Trade and Development<br>សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ |
| UNDP | United Nations Development Programme<br>កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |

# បញ្ជីតារាង

តារាងទី ២.១ ៖ ការវិនិយោគផ្ទាល់ពីបរទេសមកក្នុងកម្ពុជា......២៣
តារាងទី ៣.១ ៖ ពន្ធលើប្រាក់ចំណេញ ......៣៥
តារាងទី ៤.១ ៖ ទិន្នន័យសម្រាប់ការវិភាគ......៤៤
តារាងទី ៤.២ ៖ លទ្ធផលនៃការស្រាវជ្រាវ ......៤៤

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី ១.១ ៖ ការកើនឡើងនៃ(AD)........................................................................................ ៦
ក្រាហ្វិកទី ១.២ ៖ ការកើនឡើងនៃ(AD) និង (LARS) .................................................................................... ៨
ក្រាហ្វិកទី ១.៣ ៖ មូលហេតុនៃដែលធ្វើឲ្យមានកំណើនសេដ្ឋកិច្ច.......................................................... ៩
ក្រាហ្វិកទី ២.១ ៖ ផលិតផលជាតិសរុបរបស់ប្រទេសកម្ពុជា ..........................................................១៤
ក្រាហ្វិកទី ២.២ ៖ អត្រាកំណើនផលិតផលជាតិសរុបរបស់ប្រទេសកម្ពុជា ..........................................១៥
ក្រាហ្វិកទី ២.៣ ៖ អត្រានិកម្មភាពនៅប្រទេសកម្ពុជា.......................................................................១៦
ក្រាហ្វិកទី ២.៤ ៖ ការនាំចេញនៅប្រទេសកម្ពុជា .........................................................................១៩
ក្រាហ្វិកទី ២.៥ ៖ ការនាំចូលនៅប្រទេសកម្ពុជា ......................................................................... ២០

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១ ៖ អនុក្រឹត្យស្តីអំពី ការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

ឧបសម្ព័ន្ធទី ២ ៖ ការលើកទឹកចិត្តចំពោះអ្នកវិនិយោគក្នុង PPSEZ

ឧបសម្ព័ន្ធទី ៣ ៖ ទីតាំងភូមិសាស្ត្រ PPSEZ

ឧបសម្ព័ន្ធទី ៤ ៖ តួលេខជាក់ស្តែងនៃ PPSEZ

ឧបសម្ព័ន្ធទី ៥ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ

ឧបសម្ព័ន្ធទី ៦ ៖ តារាងការប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស

ឧបសម្ព័ន្ធទី ៧ ៖ ចំនួនអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស (គិតតាមប្រទេស)

ឧបសម្ព័ន្ធទី ៨ ៖ ទំហំទឹកប្រាក់វិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស (គិតតាមប្រទេស)

# សេចក្តីផ្តើម

## ១. លំនាំបញ្ហាការស្រាវជ្រាវ

នៅអំឡុង២ទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងកត់សម្គាល់។ ដោយមានការចូលរួមពីកត្តាជាច្រើនរួមមាន ស្ថេរភាពនយោបាយ ការកើនឡើងនៃវិស័យឯកជន និងកំណែទម្រង់សេដ្ឋកិច្ចជាច្រើនដែលធ្វើឲ្យសេដ្ឋកិច្ចនៃប្រទេសកម្ពុជាមានការកើនឡើងជាមធ្យម៧%។ ទោះបីជាមាន កំណើនសេដ្ឋកិច្ចខ្ពស់យ៉ាងណាក៏ដោយ ក៏ប៉ុន្តែដោយទំហំសេដ្ឋកិច្ចនៅតូចនៅឡើយ នោះប្រទេសកម្ពុជានៅជាប្រទេសកំពុងអភិវឌ្ឍន៍មួយដែលជាប្រទេសមានប្រាក់ចំណូលមធ្យមទាប។

បច្ចុប្បន្ន ដោយស្ថិតក្នុងដំណាក់កាលនៃដំណើរការសាកលភាវូបនីយកម្ម ប្រទេសនានាលើសកលលោក ក៏ដូចជាប្រទេសកម្ពុជា បានធ្វើកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការរៀបចំទម្រង់សេដ្ឋកិច្ចផែនការសេដ្ឋកិច្ច និងកំណែទម្រង់សេដ្ឋកិច្ចដើម្បីធ្វើឲ្យប្រទេសមានការរីកចម្រើនប្រកបដោយតម្លាភាព និងធ្វើឲ្យប្រទេសឆ្ពោះទៅកាន់ស្ថានការណ៍មួយ ដែលត្រៀមខ្លួនរួចរាល់សម្រាប់ប្រឈមមុខទៅនឹងការប្រកួតប្រជែងទៅលើវិស័យនានាជាមួយប្រទេសដទៃផ្សេងទៀតទាំងក្នុងតំបន់ និងក្រៅតំបន់។

ការអភិវឌ្ឍន៍ទៅលើតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសមួយចំនួនក្នុងតំបន់អាស៊ីទទួលបានជោគជ័យ។ តាមរយៈការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនេះ នៅចុងទសវត្សរ៍ទី២០ប្រទេសចិនបានទទួលជោគជ័យដ៏សម្បើម ដែលបានកែប្រែភូមិមួយក្នុងខេត្តShenzhenដែលប្រជាជននៅទីនោះពឹងផ្អែកចំបងទៅលើការនេសាទបែបប្រពៃណី ទៅជាទីក្រុងទំនើបមួយដែលពោពេញទៅដោយចម្រុះនៃឧស្សាហកម្ម។ ស្របពេលគ្នានោះដែរ មានលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសទៅកាន់ប្រទេសវៀតណាមជាច្រើន ដែលជាលទ្ធផលមកពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស។

ដោយមើលឃើញពីអត្ថប្រយោជន៍ពីតំបន់សេដ្ឋកិច្ចពិសេសក្នុងការទាក់ទាញវិនិយោគពីបរទេស ប្រទេសកម្ពុជាបានសម្រេចបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅឆ្នាំ២០០៥។ បន្ទាប់មកមានការរីកដុះដាលយ៉ាងខ្លាំង ដោយគិតមកត្រឹមឆ្នាំ២០១៩ តំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជាមានរហូតទៅដល់៥៤កន្លែង។ លក្ខណៈពិសេសមួយដែលគួរឲ្យគត់សម្គាល់នោះគឺ រាជរដ្ឋាភិបាលបានផ្តល់សិទ្ធក្នុងការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសទៅអ្នកអភិវឌ្ឍន៍វិស័យឯកជន។

យ៉ាងណាមិញរាជរដ្ឋាភិបាលក៏បានបង្កើតនូវគោលនយោបាយ ក៏ដូចជាច្បាប់ស្តីអំពីតំបន់សេដ្ឋកិច្ចពិសេសដើម្បីសម្រួលទៅលើដំណើរការផ្សេងៗ ដាក់កំហិតទៅលើដែនកំណត់ និងកំណត់ទៅលើស្តង់ដារមួយដែលភាគីចូលរួមទទួលបានផ្តល់ប្រយោជន៍យ៉ាងសមស្រប។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បទពិសោធន៍របស់ប្រទេសជាច្រើនដូចជា ចិន ថៃ និងវៀតណាមជាដើម បានឆ្លុះបញ្ចាំងពីភាពជោគជ័យនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស។ ក្នុងរយៈពេលជិត១៥ឆ្នាំនៃវត្តមានរបស់តំបន់សេដ្ឋកិច្ចភ្នំពេញបានធ្វើឲ្យប្រទេសកម្ពុជាទទួលបានសន្ទុះយ៉ាងគត់សម្គាល់ពីកំណើនការវិនិយោគពីបរទេស។ ដូច្នេះហើយ តាមរយៈការសិក្សាស្រាវជ្រាវនេះ យើងនឹងធ្វើការផ្តោតទៅលើបញ្ហាចោទដូចជា៖

- តើស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈយ៉ាងដូចម្តេច?
- តើដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេសមានលក្ខណៈយ៉ាងដូចម្តេច?
- តើតំបន់សេដ្ឋកិច្ចពិសេសមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងកំណើនសេដ្ឋកិច្ច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណង៖

- ស្វែងយល់អំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា
- ស្វែងយល់ពីដំណើការផ្សេងៗនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ស្វែងយល់ពីឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានផ្តល់ចំណេះដឹងឲ្យអ្នកអានយល់ដឹងកាន់តែច្បាស់ពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជម្រុញសេដ្ឋកិច្ចកម្ពុជាឲ្យកាន់តែរីកចម្រើន ព្រមទាំងដឹងកាន់តែច្បាស់អំពីដំណើរការរបស់វាផងដែរ។ ក្រោយបញ្ចប់ការស្រាវជ្រាវនេះ យើងខ្ញុំសង្ឃឹមថារដ្ឋាភិបាលនឹងខិតខំយកចិត្តទុកដាក់ទៅលើតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាឲ្យកាន់តែរីកចម្រើនបន្ថែមទៀតដើម្បីជួយដល់កំណើនសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនជានិរន្តតទៅ ។ មួយវិញទៀត សម្ពទ្ធិផលនៃការស្រាវជ្រាវមួយនេះ នឹងក្លាយជាប្រយោជន៏សម្រាប់អ្នកសិក្សាគ្រប់ៗរូប ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមពីពត៌មាន ដែលទាក់ទងទៅនឹងឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា។

## ៥. ដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះ ទំហំនៃការសិក្សាស្រាវជ្រាវនេះ គឺយើងធ្វើការសិក្សាតែក្នុងរង្វង់សេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដោយផ្តោតទៅលើតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងកំណើនសេដ្ឋកិច្ចកម្ពុជាចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩។ ចំពោះដែនកំណត់នៃការសិក្សានេះ ទិន្នន័យនិងពត៏មានទាំងឡាយដែលដកស្រង់នៅមានកម្រិត និងមានភាពខ្វះខាតដែលអាចជះឥទ្ធិពលមួយចំនួនទៅលើការបកស្រាយទិន្នន័យ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងធ្វើការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ(Quantitative Approach) ដើម្បីបកស្រាយចំណោទបញ្ហានិងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ។

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ គឺយើងធ្វើការប្រមូលទិន្នន័យទាំងឡាយណាដែលទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនៅក្នុង សៀវភៅ ឯកសារ របាយការណ៍ចេញផ្សាយនានា ដែលមានដូចជា តាមរយៈគេហទំព័ររបស់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ គេហៈទំព័ររបស់ក្រសួងសេដ្ឋកិច្ច ឯកសារតាមរយៈគេហទំព័រ (Website) ដែលមានប្រភពច្បាស់លាស់ សេចក្តីប្រកាស ដើម្បីទទួលបានទិន្នន័យដែលមានស្រាប់មួយចំនួនសម្រាប់ជាជំនួយនៅពេលធ្វើការវិភាគ និងជាឯកសារយោងផងដែរ។

ក្រោយពីប្រមូលបានទិន្នន័យទាំងអស់ហើយពួកយើងនិងធ្វើការវិភាគនៅទិន្នន័យទាំងអស់នោះក្នុងកម្មវិធី SPSS ដើម្បីធ្វើការវិភាគទៅតាមអ្វីដែលយើងបានគ្រោងទុកដែលជ្រើសរើសយកចន្លោះឆ្នាំណាមួយដើម្បីធ្វើការវិភាគបញ្ជាក់ថាវាពិតជាបានរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចកម្ពុជាពិតមែន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធានបទ "**ឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា**" ត្រូវបានបែងចែកជា ៦ផ្នែកសំខាន់ៗ ដែលមានដូចខាងក្រោម៖

**សេចក្តីផ្តើម**

សេចក្តីផ្តើម ជាចំណុចចាប់ផ្តើមនៃប្រធានបទ ដែលនឹងធ្វើការសិក្សាទៅលើផ្នែកដូចជា ស្ថានភាពទូទៅ មូលហេតុ និងគោលបំណងនៃការសិក្សា ទំហំនិងដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ។

**ជំពូកទី ១ ៖ រំលឹកទ្រឹស្តី**

នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាពីពាក្យគន្លឹះមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទ ដែលពាក្យគន្លឹះសំខាន់ៗទាំងនោះរួមមាន "តំបន់សេដ្ឋកិច្ចពិសេស និង កំណើនសេដ្ឋកិច្ច"។ និយមន័យនៃពាក្យនីមួយៗត្រូវបានដកស្រង់មកពីប្រភពឯកសារច្បាស់លាស់ ដូចជា សៀវភៅ រឺគេហទំព័រដែលអាចជឿជាក់បាន។ ម្យ៉ាងវិញទៀត នៅក្នុងចំណុចនេះដែរ យើងនឹងសិក្សាអំពីទ្រឹស្តីដែលពាក់ព័ន្ធនឹងកំណើនសេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ចពិសេសដូចជា៖

- ទ្រឹស្តី Neo-classical Theory: Solow Model
- ទ្រឹស្តី Endogenous growth Theory
- ទ្រឹស្តី Agglomeration Economies Approach

**ជំពូកទី ២ ៖ ស្ថានភាពទូទៅនៃសេដ្ឋកិច្ចនៃសេដ្ឋកិច្ចកម្ពុជា**

ក្នុងចំណុចនេះ យើងនឹងរៀបរាប់អំពីស្ថានភាពទូទៅសេដ្ឋកិច្ចកម្ពុជា ដោយផ្តោតទៅលើ កំណើនសេដ្ឋកិច្ចក្នុងរយៈពេល៥ឆ្នាំចុងក្រោយ និកម្មភាព ភាពក្រីក្រ ពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគផ្ទាល់បរទេស។ ជាមួយគ្នានេះដែរ យើងនឹងបង្ហាញអំពីប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា ដោយផ្តោតទៅលើ វិស័យសំខាន់ៗដូចជា វិស័យឧស្សាហកម្ម វិស័យកសិកម្ម និងវិស័យសេវាកម្ម។

**ជំពូកទី៣ ៖ ដំណើការនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ**

ក្នុងជំពូកនេះពួកខ្ញុំនិងធ្វើការបកស្រាយយ៉ាងលំអឹតអំពី ដំណើការនៃ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនេះដោយផ្អែកលើ ៧ ចំណុចធំៗ ៖

១ ប្រវត្តិសង្ខេបនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

២ គោលបំណងក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

៣ លក្ខខ័ណ្ឌ និងនិតិវិធី

៤ គោលនយោបាយរដ្ឋាភិបាល

៥ អត្ថប្រយោជន៍ដែលប្រទេសកម្ពុជាទទួលបានពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

**ជំពូកទី៤ ៖ ការវិភាគទិន្នន័យ**

ចំពោះជំពូកនេះវិញ យើងធ្វើការវិភាគទិន្នន័យទី២តាមប្រព័ន្ធអ៊ីនធើណេតអំពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងសេដ្ឋកិច្ចកម្ពុជា ដោយយើងនឹងយកទិន្នន័យដែលទទួលបានទាំងអស់មកវិភាគទៅតាមរយៈកម្មវិធី SDSS ដោយដំបូង កំណត់អថេរនិងគំរូវិភាគ ហើយ យកទិន្នន័យដែលទទួលបានមកវិភាគ។ តាមរយៈការវិភាគតាមកម្មវិធី SDSS យើងអាចបង្ហាញពីទំនាក់ទំនងរវាងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងកំណើនសេដ្ឋកិច្ចកម្ពុជានៅចន្លោះឆ្នាំ (២០១៥ ២០១៩)។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ជាចុងក្រោយ យើងនឹងធ្វើការសន្និដ្ឋានអំពីលទ្ធផលទាំងមូល ព្រមទាំងផ្តល់នូវអនុសាសន៍មួយចំនួនអំពីឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា។

# ជំពូកទី ១ ៖ រំលឹកទ្រឹស្តី

## ១.១ ទស្សនៈទានដែនតំបន់សេដ្ឋកិច្ចពិសេស (SEZ) និងកំណើនសេដ្ឋកិច្ច

### ១.១.១ និយមន័យតំបន់សេដ្ឋកិច្ចពិសេស

តំបន់សេដ្ឋកិច្ចពិសេស សំដៅដល់មជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចមានតំបន់ឧស្សាហកម្មទូទៅ រឺតំបន់ផលិតកែច្នៃនាំចេញ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗត្រូវមាន មណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។[1]

តំបន់សេដ្ឋកិច្ចពិសេស (SEZ) គឺជាការរៀបចំដែលមានគោលបំណងជួយប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការទាក់ទាញការវិនិយោគដែលផ្តោតលើផលិតនាំចេញ។ ល័ក្ខខ័ណ្ឌក្នុងស្រុកដែលនឹងរារាំងដល់ការវិនិយោគនេះរួមមានហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកមិនល្អ សន្តិសុខនៃការវិនិយោគ និងការរឹតបន្តឹងលើពាណិជ្ជកម្ម។ សនិទានភាពនៃតំបន់សេដ្ឋកិច្ចពិសេសគឺដើម្បីកាត់បន្ថយថ្លៃដើមដែលទាក់ទងនឹងការរាំងស្ទះទាំងនេះ ដោយហេតុនេះហើយទាក់ទាញការវិនិយោគចូលក្នុងប្រទេស។ តំបន់នេះ ធ្វើឲ្យបរិយាកាសវិនិយោគ (Investment environment) ឲ្យមានលក្ខណៈកាន់តែអំណោយផលនៅក្នុងតំបន់ភូមិសាស្ត្រមួយ។[2]

### ១.១.២ និយមន័យកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ច គឺជាការកើនឡើងនៃផលិតផលជាតិសរុបពិត (Real GDP) ដែលមានន័យថាជាការកើនឡើងនូវតម្លៃនៃទិន្នផលជាតិ និងប្រាក់ចំណូលជាតិ ហើយវាក៏ជាការកើនឡើងនៃការផលិតទំនិញនិងសេវាកម្មក្នុងរយៈពេលជាក់លាក់មួយផងដែ។ ដើម្បីឲ្យមានភាពត្រឹមត្រូវបំផុតនៅពេលគេធ្វើការវាស់វែងកំណើនសេដ្ឋកិច្ចគឺត្រូវតែដកចេញនូវផលប៉ះពាល់នៃអតិផរណា[3]។ កំណើនសេដ្ឋកិច្ចជួយបង្កើតប្រាក់ចំណេញកាន់តែច្រើនសម្រាប់អាជីវកម្មដែលជាលទ្ធផលធ្វើឲ្យតម្លៃភាគហ៊ុនកើនឡើង។ នោះផ្តល់ឲ្យក្រុមហ៊ុននូវដើមទុនដើម្បីវិនិយោគនិងជួលបុគ្គលិកបន្ថែមទៀត។ នៅពេលមានការងារកាន់តែច្រើនត្រូវបានបង្កើត ប្រាក់ចំណូលកើនឡើង។ អតិថិជនមានលុយច្រើនដើម្បីទិញផលិតផលនិងសេវាកម្មបន្ថែម ហើយការទិញនឹងជំរុញឲ្យមានកំណើនសេដ្ឋកិច្ចខ្ពស់។ ដោយហេតុផលនេះប្រទេសទាំងអស់ចង់បានកំណើនសេដ្ឋកិច្ចវិជ្ជមាននោះធ្វើឲ្យកំណើនសេដ្ឋកិច្ចសូចនាករសេដ្ឋកិច្ចត្រូវមានការឃ្លាំមើលខ្លាំងបំផុត។

[1] មាត្រា២ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

[2] https://www.adb.org/sites/default/files/publication/175236/ewp-459.pdf

[3] https://www.thebalance.com/what-is-economic-growth-3306014

### **១.១.៣ ផលិតផលជាតិសរុប** ( GDP )

គេអាចធ្វើការវាស់កំណើនសេដ្ឋកិច្ចតាមរយៈផលិតផលក្នុងស្រុកសរុប[4]ដែលជាមធ្យោបាយដ៏ល្អបំផុត ប៉ុន្តែវាត្រូវគិតគូរពីលទ្ធផលសេដ្ឋកិច្ចទាំងមូលរបស់ប្រទេសដោយរួមបញ្ចូលទាំងទំនិញនិងសេវាកម្មទាំងអស់ ដែលអាជីវកម្មនៅក្នុងប្រទេសផលិតសម្រាប់លក់។ វាមិនសំខាន់ទេថាតើពួកគេត្រូវបានលក់នៅក្នុងស្រុកឬនៅបរទេស។ ប្រទេសភាគច្រើនវាស់កំណើនសេដ្ឋកិច្ចរៀងរាល់ត្រីមាស ហើយការវាស់វែងដ៏ត្រឹមត្រូវបំផុតនៃកំណើន គឺផលិតផលក្នុងស្រុកសរុបពិតប្រាកដ ប៉ុន្តែវាត្រូវដកចេញនូវផលប៉ះពាល់នៃអតិផរណា។

ចំពោះកំណើនសេដ្ឋកិច្ចគឺជាគោលដៅម៉ាក្រូសេដ្ឋកិច្ចដ៏សំខាន់ព្រោះវាអាចជួយបង្កើននៅកម្រិតជីវភាពប្រាក់ចំណូល ចំណូលពន្ធ និងជួយបង្កើតការងារថ្មីៗ។ ជាទូទៅកំណើនសេដ្ឋកិច្ចកើតឡើងពីកត្តាចំបងធំៗពីគឺៈ

- ការកើនឡើងនូវតម្រូវការសរុប (Aggregate Demand)
- ការកើនឡើងនៃការផ្គត់ផ្គង់សរុប (Aggregate Supply)

#### **១.១.៣.១ ការកើនឡើងនូវតម្រូវការសរុប** ( Aggregate demand )

**ក្រាហ្វិកទី ១.១ ៖ ការកើនឡើងនៃ(AD)**




[4] ផលិតផលក្នុងស្រុកសរុប (GDP) គឺជាការវាស់ស្ទង់តម្លៃរូបិយវត្ថុរាល់ទំនិញនិងសេវាកម្មដែលផលិតក្នុងរយៈពេលកំណត់ណាមួយនៅក្នុងប្រទេសដែលបានផលិតក្នុងពេលកំណត់ណាមួយជាក់លាក់។ យើងអាចសរសេរកាត់ផលិតផលក្នុងស្រុកសរុបជា ផ.ស.ស ជាទូទៅត្រូវបានគេគណនាជាប្រចាំឆ្នាំ វាក៏អាចគណនាប្រចាំត្រីមាសផងដែរ។

គេទាញបានរូបមន្ត **AD = C + I + G + X- M**

- C = ការចំណាយរបស់អតិថិជន
- I = ការវិនិយោគ (ការវិនិយោគដើមទុនថេរ)
- G = ការចំណាយរបស់រដ្ឋាភិបាល
- X = ការនាំចេញ
- M = ការនាំចូល

➢ កត្តាដែលជះឥទ្ធិពលដល់តម្រូវការសរុប (AD)៖

- អត្រាការប្រាក់ទាបជាងមុន៖ អត្រាការប្រាក់ទាបកាត់បន្ថយថ្លៃដើមនៃប្រាក់កម្ចីហើយដូច្នេះលើកទឹកចិត្តដល់ការចំណាយរបស់អតិថិជននិងក្រុមហ៊ុនដើម្បីវិនិយោគ។ អត្រាការប្រាក់ទាបជាងនេះក៏កាត់បន្ថយការទូទាត់ប្រាក់កម្ចីមានទ្រព្យបញ្ចាំផងដែរដូច្នេះបង្កើនប្រាក់ចំណូលរបស់អ្នកប្រើប្រាស់។
- ការកើនឡើងប្រាក់ឈ្នួល៖ ប្រាក់ឈ្នួលពិតប្រាកដខ្ពស់បង្កើនប្រាក់ចំណូលដែលអាចប្រើបាននិងលើកទឹកចិត្តដល់ការចំណាយរបស់អ្នកប្រើប្រាស់។
- បង្កើនការចំណាយរបស់រដ្ឋាភិបាល (G) ឧទាហរណ៍៖ ការវិនិយោគរបស់រដ្ឋាភិបាលលើការកសាងផ្លូវថ្មីឬបង្កើនការចំណាយលើផលប្រយោជន៍សុខុមាលភាពដែលបង្កើនប្រាក់ចំណូលដែលអាចប្រើប្រាស់បាន។
- ការវាយតំលៃ៖ ការធ្លាក់ចុះតម្លៃនៃអត្រាប្តូរប្រាក់ (ឧ។ ផោនសឺលីង) ធ្វើឲ្យការនាំចេញមានតម្លៃថោកនិងបង្កើនបរិមាណនៃការនាំចេញ (X) ។ ការធ្លាក់ថ្លៃក៏ធ្វើឲ្យការនាំចូលមានតម្លៃថ្លៃកាត់បន្ថយបរិមាណនាំចូលនិងធ្វើឲ្យទំនិញក្នុងស្រុកកាន់តែទាក់ទាញ។
- ភាពជឿជាក់៖ ការកើនឡើងនូវទំនុកចិត្តរបស់អតិថិជនជំរុញឲ្យគ្រួសារចំណាយដោយការសន្សំប្រាក់ឬដកយកឥណទានផ្ទាល់ខ្លួនបន្ថែមទៀត។ វាអាចជួយឲ្យការចំណាយកាន់តែខ្ពស់ (C) ។ ដែលជម្រុញការចំណាយ (C) ។
- ពន្ធទាប៖ ពន្ធលើប្រាក់ចំណូលទាបនឹងជួយបង្កើនប្រាក់ចំណូលរបស់អ្នកប្រើប្រាស់និងបង្កើនការចំណាយរបស់អ្នកប្រើប្រាស់ (C) ។
- ការឡើងថ្លៃផ្ទះ៖ ការឡើងថ្លៃផ្ទះបង្កើតផលទ្រព្យសម្បត្តិវិជ្ជមាន។ ម្ចាស់ផ្ទះដែលមើលឃើញពីការកើនឡើងនៃតម្លៃផ្ទះរបស់ពួកគេនឹងមានឆន្ទៈចំណាយកាន់តែច្រើន (ផ្ទះសំរួលប្រសិនបើចាំបាច់)

- ស្ថេរភាពហិរញ្ញវត្ថុ៖ ប្រសិនបើមានស្ថេរភាពហិរញ្ញវត្ថុហើយធនាគារមានឆន្ទៈផ្តល់ប្រាក់កម្ចីនោះក្រុមហ៊ុននឹងកាន់តែមានឆន្ទៈក្នុងការវិនិយោគហើយការវិនិយោគនឹងបង្កើនតម្រូវការសរុប។

### ១.១.៣.២ ការកើនឡើងនូវផ្គត់ផ្គង់សរុប (Aggregate supply)

កំណើនសេដ្ឋកិច្ចរយៈពេលវែង (long-term economic growth) គឺជាការកើនឡើងនៃការផ្គត់ផ្គង់សរុប [សមត្ថភាពផលិតភាព(productive capacity)] ក៏ដូចជាតម្រូវការសរុប (AD) ។

**ក្រាហ្វិកទី ១.២ ៖ ការកើនឡើងនៃ(AD) និង (LARS)**




LRAS (Long run aggregate supply) ឬកំណើនសក្តានុពលអាចកើនឡើងដោយសារហេតុផលដូចខាងក្រោម[5]៖

- បង្កើនដើមទុន៖ ឧទាហរណ៍ ការវិនិយោគលើរោងចក្រថ្មីៗឬការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់និងទូរស័ព្ទ។
- ការកើនឡើងចំនួនប្រជាជនធ្វើការ៖ ឧទាហរណ៍ តាមរយៈអន្តោប្រវេសន៍អត្រាកំណើតខ្ពស់។
- បង្កើនផលិតភាពការងារ៖ តាមរយៈការអប់រំនិងការបណ្តុះបណ្តាលប្រសើរជាងមុនឬបច្ចេកវិទ្យាប្រសើរឡើង។
- ស្វែងយល់ពីវត្ថុធាតុដើមថ្មីៗ៖ ឧទាហរណ៍ ការស្វែងរកប្រេងបម្រុងនឹងបង្កើនទិន្នផលជាតិ

[5] https://www.economicshelp.org/macroeconomics/economic-growth/

- ការកែលម្អបច្ចេកវិទ្យា៖ ដើម្បីកែលម្អផលិតភាពនៃដើមទុននិងការងារ។ អ្នកផលិតមីក្រូវ៉េវនិងអ៊ីនធឺណេតបានចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច។ នៅពេលអនាគតកំណើនសេដ្ឋកិច្ចអាចមកពីបច្ចេកវិទ្យាថ្មីដូចជាបញ្ញាសិប្បនិម្មិត (AI) ដែលអាចឲ្យមនុស្សយន្តអាចជំនួសកន្លែងការងាររបស់មនុស្ស។

ក្រាហ្វិកទី ១.៣ ៖ មូលហេតុនៃដែលធ្វើឲ្យមានកំណើនសេដ្ឋកិច្ច




## ១.២ ទ្រឹស្តីនៃកំណើនសេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ចពិសេស

### ១.២.១ ទ្រឹស្តី Neo-classical Theory: Solow Model

ទ្រឹស្តីកំណើនសេដ្ឋ Neoclassical គឺជាគំរូនៃកំណើនសេដ្ឋកិច្ចដែលបង្ហាញពីលទ្ធផលនៃអត្រាកំណើនសេដ្ឋកិច្ចថេរនៅពេលដែលមានការចូលរួមពីកម្លាំងសេដ្ឋកិច្ចទាំង ៣ គឺកម្លាំងពលកម្ម មូលធន និងបច្ចេកវិទ្យា។

លោក Robert Solow និងលោក Trevor Swan ដែលទទួលបានកិត្តិនាមក្នុងការអភិវឌ្ឍ និងណែនាំគំរូកំណើនសេដ្ឋកិច្ចរយៈពេលយូរអង្វែង (long-run) ក្នុងឆ្នាំ ១៩៥៦។ វាគឺជាគំរូដំបូងដែលត្រូវបានគេចាត់ទុកថា ការកើនឡើងនូវចំនួនប្រជាជន គឺជាការកំណត់នូវអត្រាកំណើន ប៉ុន្តែក្នុងឆ្នាំ ១៩៥៧ Solow ក៏បានបញ្ចូលការផ្លាស់ប្តូរបច្ចេកវិទ្យាទៅក្នុងគំរូនេះបន្ថែមមួយទៀត។ ទ្រឹស្តីនេះសន្និដ្ឋានថា លំនឹងសេដ្ឋកិច្ចក្នុងរយៈពេលខ្លីគឺជាលទ្ធផលនៃបរិមាណពលកម្មខុសគ្នា និងមូលធនដែលដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការផលិតកម្ម។ ទ្រឹស្តីអះអាងថា ការផ្លាស់ប្តូរបច្ចេកវិទ្យាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើមុខងារទូទៅនៃសេដ្ឋកិច្ច។ ទ្រឹស្តីនៃការ

លូតលាស់តាមបែប neoclassical បានបង្ហាញពីកត្តា ៣ ដែលចាំបាច់សម្រាប់សេដ្ឋកិច្ចដែលកំពុងរីកចម្រើន។ ទោះយ៉ាងណាទ្រឹស្តីបានសង្កត់ធ្ងន់ទៅលើការអះអាងរបស់ខ្លួនថាលំនឹងបណ្តោះអាសន្នឬរយៈពេលខ្លីគឺខុសគ្នាពីលំនឹងរយៈពេលវែង និងមិនទាមទារកត្តាណាមួយក្នុងចំណោមកត្តាទាំងបីនោះទេ។

គំរូនៃការលូតលាស់តាមបែប Neoclassical អះអាងថា ការប្រមូលដើមទុននៅក្នុងសេដ្ឋកិច្ច និងរបៀបដែលប្រជាជនប្រើប្រាស់វាគឺមានសារៈសំខាន់សម្រាប់កំណត់កំណើនសេដ្ឋកិច្ច។ វាអះអាងបន្ថែមទៀតថា ទំនាក់ទំនងរវាងដើមទុននិងកម្លាំងពលកម្មនៅក្នុងសេដ្ឋកិច្ចកំណត់ពីទិន្នផលសរុបរបស់ខ្លួន។ ចុងបញ្ចប់ទ្រឹស្តីបញ្ជាក់ថាបច្ចេកវិទ្យាជួយបង្កើនផលិតភាពការងារបង្កើនទិន្នផលសរុបតាមរយៈការបង្កើនប្រសិទ្ធភាពកម្លាំងពលកម្ម។ ហេតុដូច្នេះមុខងារផលិតកម្មនៃគំរូនៃការលូតលាស់តាមបែបវិទ្យាសាស្ត្រត្រូវបានប្រើដើម្បីវាស់កំណើនសេដ្ឋកិច្ចនិងលំនឹងនៃសេដ្ឋកិច្ច។ មុខងារផលិតកម្មទូទៅនៅក្នុងគំរូនៃការលូតលាស់តាមបែបវិទ្យាសាស្ត្រមានទម្រង់ដូចខាងក្រោម[6]៖

$$Y = AF(K, L)$$

- Y បង្ហាញពីផលិតផលក្នុងស្រុកសរុបរបស់សេដ្ឋកិច្ច។
- K តំណាងឲ្យចំណែកដើមទុនរបស់វា
- L ពិពណ៌នាអំពីចំនួនកម្លាំងពលកម្មគ្មានជំនាញនៅក្នុងសេដ្ឋកិច្ច
- A តំណាងកម្រិតកំណត់នៃបច្ចេកវិទ្យា

ម្យ៉ាងវិញទៀតចំពោះឥទ្ធិពលរបស់បច្ចេកវិទ្យាទៅលើទ្រឹស្តីកំណើន គេមើលឃើថាការបង្កើនធាតុណាមួយចូលបង្ហាញពីផលប៉ះពាល់លើ GDP និង លំនឹងសេដ្ឋកិច្ច។ ទោះយ៉ាងណា ប្រសិនបើកត្តាទាំងបីនៃទ្រឹស្តីកំណើនសេដ្ឋកិច្ចមិនស្មើគ្នា នោះការត្រឡប់មកវិញនៃកម្លាំងពលកម្មគ្មានជំនាញ និងដើមទុននិងធ្វើឲ្យសេដ្ឋកិច្ចធ្លាក់ចុះ។ ផលចំណេញថយចុះទាំងនេះបញ្ជាក់ថាការកើនឡើងនូវធាតុចូលទាំងពីរនេះមានការថយចុះស្វ័យគុណស្របពេលបច្ចេកវិទ្យាគ្មានដែនកំណត់ក្នុងការរួមចំណែកដល់កំណើននិងលទ្ធផលដែលវាអាចផលិតបាន[7]។

### ១.២.២ ទ្រឹស្តី Endogenous Growth Theory

គំរូនៃការលូតលាស់ Endogenous Growth ត្រូវបានបង្កើតឡើងដោយ Paul Romer និង Robert Lucas ដែលបានសង្កត់ធ្ងន់កាន់តែខ្លាំងទៅលើគំនិតដើមទុនរបស់មនុស្ស។ របៀបដែលកម្មករមានចំណេះដឹង

[6] https://corporatefinanceinstitute.com/resources/knowledge/economics/theories-of-growth/?fbclid=IwAR1e4-e6_1z9RnXYS7rm-owJXc2nEmVfSZLYfyrJrb1g11tUy7JkqTz917M
[7] https://www.investopedia.com/terms/n/neoclassical-growth-theory.asp

ការអប់រំ និងការបណ្តុះបណ្តាលកាន់តែច្រើនអាចជួយបង្កើនអត្រានៃការរីកចម្រើនខាងបច្ចេកវិទ្យា។ ដើម្បីបង្ហាញពីវិធីសាស្ត្រនៃការលូតលាស់ Endogenous គេពិនិត្យមើលគំរូនៃ Endogenous Growth របស់ Paul Romer វាផ្តោតលើការលេចចេញនូវបច្ចេកវិទ្យា (ក្នុងនោះផលិតភាពរបស់ក្រុមហ៊ុនឬឧស្សាហកម្មមួយនាំឲ្យមានការកើនឡើងនូវផលិតភាពនៅក្នុងក្រុមហ៊ុនឬឧស្សាហកម្មផ្សេងទៀត) ដែលអាចមាននៅក្នុងដំណើរការនៃឧស្សាហូបនីយកម្ម។ ដូច្នេះវាមិនត្រឹមតែជាគំរូ Endogenous Growth ប៉ុណ្ណោះទេប៉ុន្តែវាក៏ជាផ្នែកមួយនៃទំនាក់ទំនងជាក់លាក់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ គំរូចាប់ផ្តើមដោយសន្មតថាដំណើរការលូតលាស់ទទួលបានពីកម្រិតក្រុមហ៊ុនឬឧស្សាហកម្ម។ ឧស្សាហកម្មនីមួយៗផលិតរៀងៗខ្លួនជាមួយនឹងផលចំណេញថេរដូច្នេះម៉ូដែលគឺស្របជាមួយនឹងការប្រកួតប្រជែងដ៏ល្អឥតខ្ចោះ[8]។

ទ្រឹស្តីនៃការលូតលាស់ Endogenous Growth បានថៃងថាកំណើនសេដ្ឋកិច្ចត្រូវបានបង្កើតនៅខាងក្នុងសេដ្ឋកិច្ចពោលគឺតាមរយៈកម្លាំងដែលគ្មានថាមពលនិងមិនមែនតាមរយៈកម្លាំងខាងក្រៅទេ។ ទ្រឹស្តីនេះផ្ទុយនឹងគំរូនៃការលូតលាស់តាមបែបវិទ្យាសាស្ត្រដែលអះអាងថា កត្តាខាងក្រៅដូចជាវឌ្ឍនភាពបច្ចេកវិទ្យាជាដើមគឺជាប្រភពសំខាន់នៃកំណើនសេដ្ឋកិច្ច[9]។ ពួកគេផ្តោតសំខាន់លើតម្រូវការសម្រាប់រដ្ឋាភិបាលក្នុងការជំរុញការច្នៃប្រឌិតបច្ចេកវិទ្យាយ៉ាងសកម្ម។ ពួកគេជជែកវែកញែកនៅក្នុងទស្សនៈទីផ្សារសេរីបែបបុរាណ ក្រុមហ៊ុនប្រហែលជាគ្មានការលើកទឹកចិត្តក្នុងការវិនិយោគលើបច្ចេកវិទ្យាថ្មីទេពីព្រោះពួកគេនឹងតស៊ូដើម្បីទទួលបានអត្ថប្រយោជន៍នៅក្នុងទីផ្សារប្រកួតប្រជែង[10]។ គំរូបានសង្កត់ធ្ងន់ទៅលើ៥ចំណុច ៖

- ការផ្តោតលើការបង្កើនទាំងដើមទុននិងផលិតភាពការងារ។
- រដ្ឋថាការបង្កើនផលិតភាពការងារមិនធ្វើឲ្យផលចំណេញថយចុះនោះទេប៉ុន្តែប្រហែលជាមានការកើនឡើងនូវប្រាក់ចំណូល
- ពួកគេអះអាងថាការបង្កើនដើមទុនមិននាំឲ្យប្រាក់ចំណេញថយចុះដូចដែលសូឡូសូបានព្យាករណ៍ទេ។ពួកគេនិយាយថាវាកាន់តែស្មុគស្មាញហើយវាអាស្រ័យលើប្រភេទនៃការវិនិយោគដើមទុន។
- បង្កើនសារៈសំខាន់នៃការហូរចេញអត្ថប្រយោជន៍ពីសេដ្ឋកិច្ចផ្អែកលើចំណេះដឹង។
- ការសង្កត់ធ្ងន់ត្រូវបានដាក់នៅលើទីផ្សារសេរីកាត់បន្ថយបទប្បញ្ញត្តិនិងការឧបត្ថម្ភធន។

[8] Todaro, M, P, & Smith, S ,C.*Economic development* (11th eds.) [សេដ្ឋកិច្ចអភិវឌ្ឍន៍]. (Boston:Addison-Weslay).១៥២។

[9] https://www.investopedia.com/terms/e/endogenousgrowththeory.asp

[10] https://www.economicshelp.org/blog/57/growth/explaining-theories-of-economic-growth/

### ១.២.៣ ទ្រឹស្តី Agglomeration Economies Approach

វិធីសាស្ត្រនេះ មិនមែនផ្តោតសំខាន់ទៅលើការបង្កើនធនធានដើម្បីកំណើនសេដ្ឋកិច្ចនោះទេ ប៉ុន្តែផ្តោតលើការរៀបចំធនធានទាំងនោះក្នុងគោលបំណងការលើកកម្ពស់ផលិតភាពនិងភាពច្នៃប្រឌិត។ គុណសម្បត្តិនៃ agglomerations គឺ រីកសាយភាយនូវចំណេះដឹង (Knowledge spillover) ការចែករំលែកធនធាននិងការប្រមូលផ្តុំកម្លាំងពលកម្ម(Labor pooling)។

តំបន់សេដ្ឋកិច្ចពិសេសជាការប្រមូលផ្តុំវីជាចង្កោមនៃសហគ្រាសបរទេសនិងក្នុងស្រុកដែលមានការគាំទ្រពីរដ្ឋាភិបាល។ ចង្កោមនេះជួយបង្កើនផលិតភាពនិងជំរុញការច្នៃប្រឌិតតាមរយៈការប្រមូលផ្តុំបច្ចេកវិទ្យាព័ត៌មាន ជំនាញ ទេពកោសល្យ ក្រុមហ៊ុនដែលមានការប្រកួតប្រជែង ស្ថាប័នសិក្សានិងអង្គភាពដទៃទៀត។ ភាពជោគជ័យនៃចង្កោមនេះគឺអាស្រ័យលើកត្តា ៤ យ៉ាងគឺ រចនាសម្ព័ន្ធក្រុមហ៊ុន យុទ្ធសាស្ត្រនិងគូប្រជែង ស្ថានភាពនៃតំរូវការ និងឧស្សាហកម្មគាំទ្រ(Supporting industries)។ អន្តរកម្មកាន់តែខ្លាំងនិងអភិវឌ្ឍអន្តរកម្មនៃកត្តាទាំងនេះកាន់តែច្រើន វានឹងធ្វើឲ្យផលិតភាពកាន់តែខ្ពស់។ លើសពីនេះទៅទៀតនោះ ការប្រមូលផ្តុំនៃសហគ្រាសបរទេសនិងក្នុងស្រុក នឹងពង្រីកអត្ថប្រយោជន៍ទាំងនេះបន្ថែមទៀត។ ភាពជិតស្និទ្ធរវាងសហគ្រាសបរទេសនិងក្នុងស្រុក និងការភ្ជាប់ទំនាក់ទំនងនឹងជួយសម្រួលដល់ ការរីកសាយភាយនូវបច្ចេកវិទ្យា (Technological spillover) និងឥទ្ធិពលនៃនៃការបង្ហាញ(Demonstration effects)។ សហគ្រាសដែលនៅក្នុងចង្កោមភ្ជាប់នេះ បង្កើតនូវទំនាក់ទំនងជាមួយនឹងតួអង្គខាងក្រៅនិងបង្កើនការប្រកួតប្រជែងរបស់ពួកគេផងដែរ។[11]

សេដ្ឋកិច្ចប្រមូលផ្តុំ (Agglomeration economies) គឺកើតឡើងនៅពេលដែលទីក្រុងមួយក្នុងទ្រង់ទ្រាយធំត្រូវបានបង្កើតឡើងដោយសារតែវានឹងផ្តល់នូវផលចំណេញលើថ្លៃដើម (Cost advantage) ដល់អ្នកផលិតនិងអ្នកប្រើប្រាស់។ យោងតាមលោក Walter Isard សេដ្ឋកិច្ចប្រមូលផ្តុំនេះមានពីរទម្រង់។ Urbanization economies ជាឥទ្ធិពលដែលទាក់ទងទៅនឹងកំណើនទូទៅនៃតំបន់ភូមិសាស្ត្រមួយ។ ចំណែកឯ Localization economies ជាឥទ្ធិពលដែលកើតឡើងពីកំណើននៃវិស័យជាក់លាក់ណាមួយនៃសេដ្ឋកិច្ចដូចជាហិរញ្ញវត្ថុឬថយន្ត។ Local economies ចែកជាពីរទម្រង់គឺ backward linkage និងforward linkage។ អត្ថប្រយោជន៍មួយនេះនៃ forward linkage កើតឡើងនៅពេលដែលថ្លៃដើមនៃការដឹកជញ្ជូនមានសារៈសំខាន់ អ្នកប្រើប្រាស់ផលិតផលរបស់វិស័យណាមួយនោះនឹងទទួលបានអត្ថប្រយោជន៍ដែលវាជួយកាត់

---

[11] Aradhna, A. *Economic impacts of SEZs: Theoretical approaches and analysis of newly notified SEZs in India.* (India, 2010).

បន្ថយនូវថ្លៃមួយចំនួនដោយសារតែមានទីតាំងនៅក្បែរ។ ហើយ សហគ្រាសដែលស្ថិតនៅក្នុងវិស័យតែមួយឬជាប់ពាក់ព័ន្ធនឹងទទួលបានអត្ថប្រយោជន៍ពីការដាក់ទីតាំងនៅជិតគ្នាឬក្នុងទីក្រុងតែមួយ។ តាមរយៈការដាក់ទីតាំងនៅជិតគ្នាឬក្នុងទីក្រុងតែមួយនេះ សហគ្រាសទាំងនោះនឹងទទួលបានបុគ្គលិកជាច្រើនដែលមានជំនាញក្នុងវិស័យនោះ។ អត្ថប្រយោជន៍បែបនេ ហៅថា backward linkage។ ស្របពេលគ្នានោះដែរ បុគ្គលិកជាច្រើនដែលមានជំនាញក្នុងវិស័យនោះក៏មានទំនរក្នុងការមករស់នៅក្នុងទីក្រុងនេះដែរ ព្រោះថាពួកគេ នឹងមានភាពងាយស្រួលក្នុងការស្វែងរកការងារថ្មីឬឱកាសដ៏ល្អប្រសើរក្នុងការទទួលបានមុខតំណែងខ្ពស់។[12]

[12] Todaro, M, P, & Smith, S ,C.*Economic development* (11th eds.) [សេដ្ឋកិច្ចអភិវឌ្ឍន៍]. (Boston:Addison-Weslay).១៥២។

# ជំពូកទី ២៖ ស្ថានភាពទូទៅនៃសេដ្ឋកិច្ចកម្ពុជា

## ២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

### ២.១.១ កំណើនសេដ្ឋកិច្ច

ដោយកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចបើកចំហក្នុងតំបន់អាស៊ី កំណើនសេដ្ឋកិច្ចមានការប្រាស័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់អាស៊ី។ ជាក់ស្តែងណាស់ វិបត្តិហិញ្ញវត្ថុឆ្នាំ ២០០៨-២០០៩ បានបណ្តាលឲ្យសេដ្ឋកិច្ចកម្ពុជាទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលធ្វើឲ្យកំណើនសេដ្ឋិច្ចកម្ពុជាធ្លាក់ចុះយ៉ាងគំហុក ជាងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ីដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា។ ប៉ុន្តែ កម្ពុជាជាប្រទេសមួយចំនួនតូចក្នុងតំបន់ដែលអាចងើបឡើងវិញបានយ៉ាងឆាប់រហ័ស។

**ក្រាហ្វិកទី ២.១ ៖ ផលិតផលជាតិសរុបរបស់ប្រទេសកម្ពុជា**




ទោះបីជាប្រទេសកម្ពុជា នៅជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ប៉ុន្តែសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងក្នុងទំហំមួយគួរឲ្យកត់សម្គាល់។ ក្នុងអំឡុងពេល២ទសវត្សចុងក្រោយនេះ អត្រាកំណើនសេដ្ឋកិច្ចមធ្យមមានកម្រិតប្រមាណ ៧%។ តាមរយៈការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ អាចឆ្លុះបញ្ចាំងឲ្យឃើញកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយនិងធ្វើកំណែទម្រង់ផ្សេងៗក្នុងគោលបំណងឈានទៅរកកំណើនសេដ្ឋកិច្ចជាបន្តបន្ទា

ប់។ ផលិតផលជាតិសរុប (GDP) មានការបម្រែបម្រួលវិជ្ជមានដែលក្នុងឆ្នាំ២០១៥ មានតម្លៃប្រមាណ ១៨.០៥ ពាន់លានដុល្លារសហរដ្ឋអាមេរិក បានកើនឡើងរហូតដល់ ២៧.០៩ ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៩។

**ក្រាហ្វិកទី ២.២ ៖ អត្រាកំណើនផលិតផលជាតិសរុបរបស់ប្រទេសកម្ពុជា**




*ប្រភព: Asian Development Bank (ADB)*

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ២០១៩ មានភាពល្អប្រសើរ ដោយសេដ្ឋកិច្ចបន្តសម្រេចបានកំណើនរហូតដល់ ៧.១% ដែលគាំទ្រដោយកំណើនដ៏រឹងមាំនៃវិស័យកាត់ដេរ វិស័យកសិកម្ម វិស័យសំណង់ និងវិស័យទេសចរណ៍។ កំណើនសេដ្ឋកិច្ចនេះផងដែរ ក៏មានទំនាក់ទំនងជាមួយនឹងនិកម្មភាពនិងភាពក្រីក្រ។

## ២.១.២ និកម្មភាព

និកម្មភាពនៅកម្ពុជាស្ទើរតែត្រូវបានលុបបំបាត់ចោលបានទាំងស្រុង តាមរយៈទិន្នន័យពីការសិក្សាថ្មីៗនេះបានបង្ហាញថាប្រជាជនតិចជាងមួយភាគរយកំពុងប្រឈមនឹងភាពអត់ការងារធ្វើ ។ បើពិនិត្យមើលទៅលើទិន្នន័យពីអង្គការពលកម្មអន្តរជាតិ (ILO) ២០១៦-២០១៩ ថាប្រជាជនកម្ពុជាប្រមាណ ៩៩.៣ ភាគរយមានការងារធ្វើ។ ទិន្នន័យរបស់ប្រជាជនកម្ពុជាដែលមានការងារធ្វើគឺស្ថិតនៅកម្រិតមួយដែលខ្លាំង ដូច្នេះយើងអាចនិយាយបានថាស្ទើរតែគ្រប់គ្នាមានការងារធ្វើ។ អ្វីដែលនៅសេសសល់មានតែ ០,៧ ភាគរយប៉ុណ្ណោះដែលមិនមានការងារធ្វើ″ ។

## ក្រាហ្វិកទី ២.៣ ៖ អត្រានិកម្មភាពនៅប្រទេសកម្ពុជា




*ប្រភព: ធនាគារពិភពលោក*

ជាមួយតួលេខនេះ យើងឃើញថា វិស័យសេដ្ឋកិច្ចទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ផ្តល់ការងារកម្មករប្រមាណ ៣,៧ លាននាក់ ខណៈវិស័យកសិកម្ម ផ្តល់ការងារកម្មកររហូតដល់ ៤ លាននាក់ មានន័យថាមួយផ្នែកដ៏ធំនៃកម្លាំងពលកម្មនៅតែបន្តពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្មនិង ៥០០.០០០ នាក់ទៀតជាមន្ត្រីសាធារណៈ។ លើសពីនេះទៅទៀតប្រជាជនកម្ពុជាជាងមួយលាននាក់បានធ្វើការនៅក្រៅប្រទេសនៅក្នុងប្រទេសដូចជា ប្រទេសថៃ ប្រទេសម៉ាឡេស៊ី និងប្រទេសជប៉ុនហើយបានបញ្ជូនប្រាក់ចំនួន ១,៧ លានដុល្លារត្រឡប់ទៅគ្រួសាររបស់ពួកគេជារៀងរាល់ឆ្នាំ។

ទោះយ៉ាងណាក៏ដោយ ចំនួនម៉ោងធ្វើការក្នុងមួយសប្តាហ៍របស់មនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជាមានចំនួនតិចតួចជាពិសេសការលក់តាមផ្លូវ ស្របពេលគ្មាននោះដែរ ពួកគេស្វែងរកការងារផ្សេងៗទៀតដែលជាប្រភពចំណូលបន្ថែម។ មនុស្សជាច្រើនមានការងារច្រើនជាងមួយពីព្រោះប្រាក់ឈ្នួលដែលពួកគេទទួលបានទាបពេក។ ៥១ ភាគរយនៃការងារនៅក្នុងប្រទេសកម្ពុជាគឺជាការងារដែលងាយរងគ្រោះ "vulnerable jobs"។ ប្រជាជនដែលមានការងារងាយរងគ្រោះមិនទទួលប្រាក់ខែទេ ឧទាហរណ៍ ពួកគេធ្វើការជាកសិករឬធ្វើការគ្រួសាររបស់ពួកគេ។ ភាគច្រើនគឺជាអ្វីដែលអ្នកសេដ្ឋកិច្ចកំពុងហៅថា "underemployed" ដែលមានន័យថាការងារដែលបានមិនទទួលបានប្រាក់ខែគ្រប់គ្រាន់ ឬការងារដែលមិនចំបាច់ប្រើជំនាញនិងប្រើប្រាស់សមត្ថ

ភាពពេញលេញនោះទេ[13]។ ទោះបីជាមានការប្រែប្រួលមួយផ្នែកពីវិស័យកសិកម្មទៅឧស្សាហកម្មនិងវិស័យសេវាកម្មក៏ដោយ ក៏ប៉ុន្តែការងារទាំងនោះសុទ្ធសឹងតែទាមទារឲ្យមានជំនាញខ្ពស់។ ដូច្នេះហើយវាពិតជាមានការលំបាកចំពោះកម្មករអត់ជំនាញក្នុងការប្រាតចូលជាពិសេសវិស័យសេវាកម្ម។ ភាពអត់ការងារធ្វើ រួមចំណែកធ្វើឲ្យមានការខ្វះខាតប្រាក់ចំណូល ដែលបន្ទាប់មកនាំឲ្យកម្រិតជីវភាពគ្រួសារមានភាពលំបាក។

### ២.១.៣ ភាពក្រីក្រ

រដ្ឋាភិបាលកម្ពុជាប៉ាន់ស្មានពីភាពក្រីក្រដែលផ្អែកលើទិន្នន័យការប្រើប្រាស់ក្នុងគ្រួសារ។ នៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ (NPRS) ខ្សែបន្ទាត់ភាពក្រីក្រនៃអាហារត្រូវបានប៉ាន់ប្រមាណដោយបរិមាណទទួលទានអាហារដែលមានតម្រូវការអាហារូបត្ថម្ភអប្បបរមាសម្រាប់ការរស់រាន ២១០០kcal ។ ម្ហូបអាហារដែលត្រូវបានប្រើដើម្បីគណនាកម្រិតនៃការប្រើប្រាស់អប្បបរមាគឺផ្អែកលើទិន្នន័យពី CSES 1993/94។

ដើម្បីប្រៀបធៀបការផ្លាស់ប្តូរភាពក្រីក្រតាមពេលវេលា វាចាំបាច់ត្រូវកែសម្រួលខ្សែបន្ទាត់ភាពក្រីក្រដោយការផ្លាស់ប្តូរតម្លៃនៃបរិមាណប្រើប្រាស់ និងភាពខុសគ្នានៃតម្លៃចន្លោះ(spatial price)។[14]

| Absolute Poverty Line = Food Poverty Line + Minimum non-food consumption<br>(minimum food consumption) |
|---|

យ៉ាងណាមិញប្រជាជនដែលរស់នៅតាមជនបទ ភាគច្រើនធ្វើការក្នុងវិស័យកសិកម្ម។ ការស្រាវជ្រាវជាច្រើនបង្ហាញថាប្រហែល ៣៣,៣ ភាគរយនៃប្រជាជនសរុបដែលមានការងារធ្វើនៅក្នុងប្រទេសកម្ពុជាធ្វើការនៅក្នុងឧស្សាហកម្មកសិកម្ម។ ស្រដៀងនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ ប្រជាពលរដ្ឋដែលធ្វើការក្នុងវិស័យកសិកម្មទទួលរងនូវភាពងាយរងគ្រោះពីបញ្ហាគ្រោះធម្មជាតិដូចជា ទឹកជំនន់និងគ្រោះរាំងស្ងួតជាដើម។ ទន្ទឹមនឹងនេះដែរ តម្លៃកសិផលស្ថិតនៅកម្រិតទាបនៅលើយដោយសារតែការផ្គត់ផ្គង់ខ្ពស់ ជាពិសេសបន្ទាប់ពីរដូវប្រាំង។

កង្វះសន្តិសុខការងារនៅកម្ពុជាមានការរីករាលដាល។ ភាគច្រើននៃប្រជាជនកម្ពុជាធ្វើការនៅក្នុងវិស័យក្រៅផ្លូវការហើយពួកគេជួបប្រទះភាពងាយរងគ្រោះ។ អសន្តិសុខការងារត្រូវបានរីករាលដាលនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយវាធ្វើឲ្យបុគ្គលម្នាក់ៗអាចបាត់បង់ការងារធ្វើយ៉ាងឆាប់រហ័ស។ កម្មករទទួលបានប្រាក់ឈ្នួលទាប ដូច្នេះពួកគេអាចសន្សំប្រាក់បានតិចតួចដែលបង្ហាញថាពួកគេស្ទើរតែចូលរួមឬរួមចំណែកមួយផ្នែក

[13] International Labor Organization. *World Employment and Social Outlook*. (2019).

[14] JICA. *Study for Poverty Profiles in the Asian Region*. (2010)

តូចក្នុងការវិនិយោគចូលទៅក្នុងប្រព័ន្ធសេដ្ឋកិច្ច។ ការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនទទួលបាននូវអត្ថប្រយោជន៍ធានារ៉ាប់រងនិងប្រាក់សោធននិវត្តន៍នោះទេ ដូច្នេះវាធ្វើឲ្យស្ថានភាពហិរញ្ញវត្ថុរបស់ភាពក្រីក្រនៅកម្ពុជាកាន់តែអាក្រក់ទៅៗ។ ប្រទេសកម្ពុជា នៅតែជាប្រទេសដែលក្រីក្រជាងគេនៅអាស៊ាន បើយើងវាស់តាម GNI ក្នុងមនុស្សម្នាក់ៗ (ធនាគារពិភពលោកឆ្នាំ ២០១៦) ។ ខណៈពេលដែលកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់កម្ពុជា បានធ្វើឲ្យខ្លួនក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥។

យោងតាម UNDP ក្នុងឆ្នាំ២០១៨ ប្រជាជនកម្ពុជា៣៥% នៅតែកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រអន្តរជាតិដែលមានអត្រា ១,៩០ ដុល្លារក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ។ ៤០% នៃប្រជាជននៅជនបទនៃប្រទេសកម្ពុជារស់នៅក្នុងភាពក្រីក្រ ខណៈដែលប្រជាជនកម្ពុជា ៤៥% ដែលរស់នៅក្នុងភាពក្រីក្រមានអាយុ ១៩ ឆ្នាំឬក្មេងជាងនេះ។ ប្រជាជនកម្ពុជាជាង ៨,១ លាននាក់ជិតក្រហើយមានន័យថា ប្រសិនបើពួកគេខាតបង់ ៣០ សេននៃប្រាក់ចំណូលក្នុងមួយថ្ងៃពួកគេនឹងធ្លាក់ចូលទៅក្នុងខ្សែបន្ទាត់ភាពក្រីក្រវិញ។ ដូចគ្នានេះផងដែរ ការចែកចាយមិនស្មើភាពនៃផលសេដ្ឋកិច្ច មានន័យថាប្រជាជនកម្ពុជាជាច្រើននៅតែទទួលបាននូវកម្រិតគុណភាពទាបទៅលើផ្នែកសុខភាព ការអប់រំជំនាញនិងការងារ និងបាត់បង់ឱកាសក្នុងការទទួលបានសេវាកម្មចាំបាច់មួយចំនួន[15]។

### ២.១.៤ ពាណិជ្ជកម្មអន្តរជាតិ

ជាមួយនឹងយន្តការទីផ្សារសេរី ប្រទេសកម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងទីផ្សារពិភពលោក និងតំបន់។ ប្រទេសកម្ពុជា បានចូលជាសមាជិកនៃសហគមន៍អាស៊ាន(ASEAN) ការពាណិជ្ជកម្មពិភពលោក។ តាមរយៈសមាហរណកម្មសេដ្ឋកិច្ចនេះ ប្រទេសកម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមួយដែលមានសន្ទុស្សន៍វិជ្ជមានទៅលើវិស័យពាណិជ្ជកម្ម។ ជាងនេះទៅទៀតនោះ ប្រទេសកម្ពុជា ស្ថិតក្នុងទីតាំងយុទ្ធសាស្ត្រនៅតំបន់អាស៊ីអាគ្នេយ៍។ ដោយមានកំពង់ផែធំមួយនៅឈូងសមុទ្រថៃ ហើយប្រទេសកម្ពុជាក៏មានព្រំដែនផ្លូវគោកជាប់ជាមួយប្រទេសថៃ ប្រទេសឡាវនិង ប្រទេសវៀតណាមផងដែរ។ ប្រទេសកម្ពុជា បានដឹកជញ្ជូនទំនិញតាមកាប៉ាល់ទៅជុំវិញពិភពលោកប្រមាណ ២៥,២ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០១៩ ។ ចំនួនទឹកប្រាក់នេះឆ្លុះបញ្ចាំងពីការកើនឡើង ១៩៥% ចាប់តាំងពីឆ្នាំ ២០១៥ និង ៩៨,២% កើនឡើងពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០១៩ [២]។ ប្រទេសកម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៥៤ រហូតមកដល់បច្ចុប្បន្ន។ អាជីវកម្មដែលកំពុងដំណើរការចេញពីតំបន់សេដ្ឋកិច្ចពិសេសទាំងនេះអាចនាំចូលវត្ថុធាតុដើមនិងឧបករណ៍ផលិតកម្ម

[15] https://www.humanandhsopeassociation.org/poverty/

ដោយមិនបង់ពន្ធនាំចូលហើយត្រូវបានលើកលែងពីអាករលើតម្លៃបន្ថែមទាំងការនាំចេញនិងនាំចេញ។ ផលវិជ្ជមានដែលមកពីវិស័យពាណិជ្ជកម្មនេះ នឹងជំរុញដល់កំណើនសេដ្ឋកិច្ច ស្របបពេលគ្នានោះដែរ ក៏ជួយកាត់បន្ថយភាពក្រីក្រផងដែរ។

### ២.១.៤.១ ការនាំចេញ

ការនាំចេញទំនិញទៅគ្រប់ទីបក្រោមប្រព័ន្ធអណុគ្រោះពាណិជ្ជកម្មសេរី ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៩ មានទឹកប្រាក់ប្រមាណជាង ១០ ៨១៣លានដុល្លារអាមេរិក បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨ ដែលមានទឹកប្រាក់ប្រមាណជាង ១០ ១៥៨លានដុល្លារអាមេរិក កើនឡើងប្រមានជាង ៦៥៤លានដុល្លារអាមេរិក ស្មើនឹង ៦,៤៥%។ ក្នុងនោះមានសម្លៀកបំពាក់ (Garments) មានទឹកប្រាក់ប្រមាណជាង៦៤០៦លានដុល្លារអាមេរិក វាយនភ័ណ្ឌ មានទឹកប្រាក់ប្រមាណជាង៤០លានដុល្លារអាមេរិក ស្បែកជើង មានទឹកប្រាក់ប្រមាណជាង ៩០៥ លានដុល្លារអាមេរិក អង្ករ មានទឹកប្រាក់ប្រមាណជាង ២៨៦ លានដុល្លារអាមេរិក និងផលិតផលផ្សេងៗ មានទឹកប្រាក់ប្រមាណជាង ១៧៤ លានដុល្លារអាមេរិក។[16]

**ក្រាហ្វិកទី ២.៤ ៖ ការនាំចេញនៅប្រទេសកម្ពុជា**




ក្នុងទំហំម៉ាក្រូសេដ្ឋកិច្ច ទំនិញដែលបាននាំចេញសរុបរបស់កម្ពុជាតំណាងឲ្យ ៣២,៧% នៃផលិតផលក្នុងស្រុកសរុបរបស់ខ្លួនសម្រាប់ឆ្នាំ ២០១៩ (៧៧ ពាន់លានដុល្លារគិតតាមPPP) ។ ចំនួននោះ ៣២,៧%

[16] ក្រសួងពាណិជ្ជកម្ម, *របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០១៩ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២០*

សម្រាប់ការនាំចេញផលិតផលសរុបក្នុងផ.ស.សសម្រាប់ឆ្នាំ ២០១៩ បើប្រៀបធៀបនឹង ឆ្នាំ ២០១៨ បានតែ ២៧%ប៉ុណ្ណោះ។

ដោយសារការបន្តកំណើនសេដ្ឋកិច្ចក្នុងប្រទេសដៃគូពាណិជ្ជកម្មធំៗ ទស្សនវិស័យនៃការនាំចេញរបស់កម្ពុជានៅតែមានសក្តានុពល។ ជាមួយគ្នានេះ ក៏មានការកត់សម្គាល់ផងដែរថា ការនាំចេញរបស់កម្ពុជាត្រូវបានធ្វើពិពិធកម្មជាបន្តបន្ទាប់ទាំងផលិលផល និងទីផ្សារនាំចេញ ពោលគឺ ពីការនាំចេញផលិតផលកាត់ដេរទៅផលិតផលផ្សេងទៀត និងពីទីផ្សារអាមេរិក ទៅទីផ្សារផ្សេងទៀត។

### ២.១.៤.២ ការនាំចូល

ប្រទេសកម្ពុជា បានភាគច្រើននាំចូលផលិតផលប្រើប្រាស់ប្រចាំថ្ងៃនិងឧបករណ៍អេឡិចត្រូនិចដែលជាផលិតផលសម្រេច ស្របពេលគ្នានេះដែរ ក៏នៃចូលវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ រថយន្ត ប្រេង និងសំភារៈសំណង់ផងដែរ។

ការនាំចូលរបស់កម្ពុជាភាគច្រើនមកពីប្រទេសចិនដែលមានចំនួន ៤៣,១ ភាគរយនៃចំនួនសរុបនៅឆ្នាំ ២០១៩ ។ ប្រទេសថៃឈរនៅលំដាប់ទី២ (១៥,៥ភាគរយ) វៀតណាម (១៣,៦ ភាគរយ) ជប៉ុន (៤,៧ ភាគរយ) និងកូរ៉េខាងត្បូង (៣,៤ ភាគរយ) ។

**ក្រាហ្វិកទី ២.៥ ៖ ការនាំចូលនៅប្រទេសកម្ពុជា**




ការនាំចូលសរុបរបស់កម្ពុជាមានចំនួន ២២ ១៩០ ពាន់លានដុល្លារក្នុងខែធ្នូឆ្នាំ២០១៩។ ហើយយោងតាមក្រសួងពាណិជ្ជកម្ម ការនាំចូលតាមរយៈអាជ្ញាប័ណ្ណ មានទឹកប្រាក់ប្រមាណជាង៧៨ម៉ឺនដុល្លារអាមេ

រិក បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨ ដែលមានទឹកប្រាក់ប្រមាណ៣លានដុល្លារអាមេរិក ថយចុះប្រមាណជាង២លានដុល្លារអាមេរិក ស្មើនឹង២៧៥%។[17]

### ២.១.៤.៣ ការអនុគ្រោះពន្ធពីបរទេស

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលទទួលផលមួយនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ដែលដំណើរការដោយប្រទេសអភិវឌ្ឍន៍។ នៅក្រោមគ្រោងការណ៍នេះ ពន្ធនាំចូលលើផលិតផលជាច្រើនត្រូវបានលើកលែងឬកាត់បន្ថយ ប្រសិនបើលក្ខខណ្ឌចាំបាច់ដែលត្រូវការបានបំពេញគ្រប់គ្រាន់។ តាមរយៈប្រព័ន្ធនេះ ប្រទេសកម្ពុជា ទទួលបានផលប្រយោជន៍ជាច្រើនពីទីផ្សារធំៗគឺ ជប៉ុន ចិន សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ សហភាពអឺរ៉ុបធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រទេសកម្ពុជា ក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការអឺរ៉ុប-អាស៊ាន ដើម្បីធានាបាននូវប្រសិទ្ធភាពនៃទំនាក់ទំនងពាណិជ្ជកម្មនិងវិនិយោគ។[18]

ប្រទេសកម្ពុជា គឺជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកចាប់តាំងពីឆ្នាំ ២០០៤ ហើយក្នុងនាមជាប្រទេសដែលមានការអភិវឌ្ឍតិចតួច (LDC) ទទួលបានអត្ថប្រយោជន៍ពីគម្រោង EBA របស់សហភាពអឺរ៉ុបដែលផ្ដល់ជូននូវ Duty free និងមិនកំណត់បរិមាណ (Quota) សម្រាប់ការនាំចេញទាំងអស់លើកលែងតែសភាវុធ។ នៅឆ្នាំ ២០១៩ ពាណិជ្ជកម្មលើទំនិញសរុបរវាងសហភាពអឺរ៉ុបនិងកម្ពុជាស្មើនឹង ៥,៦ ពាន់លានអឺរ៉ូ។ សហភាពអឺរ៉ុបជាប់ចំណាត់ថ្នាក់ជាដៃគូពាណិជ្ជកម្មធំទី ២ របស់កម្ពុជា (បន្ទាប់ពីប្រទេសចិន) ដែលមានចំនួន ១១,៩% នៃពាណិជ្ជកម្មសរុបរបស់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជា គឺជាដៃគូពាណិជ្ជកម្មធំជាងគេទី ៥៤ ដែលមានទំហំពាណិជ្ជកម្មស្មើនឹង ០,១% នៃពាណិជ្ជកម្មសរុបរបស់សហភាពអឺរ៉ុប។ ការនាំចេញវាយនភ័ណ្ឌនិងស្បែកជើង កង់ គ្រឿងឧបភោគបរិភោគនិងផលិតផលបន្លែ (អង្ករ) មានចំនួន ៩៥% នៃការនាំចេញសរុបរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបក្នុងឆ្នាំ ២០១៩។ ក្រៅពីការនាំចេញសរុបប្រហែល ៩៨% មានសិទ្ធិទទួលបានអនុគ្រោះអនុគ្រោះ EBA[19]។

ប៉ុន្តែក្នុងរយៈពេលថ្មីៗនេះ គណៈកម្មការអឺរ៉ុបបានសម្រេចដកមួយផ្នែកនៃអនុគ្រោះពន្ធដែលបានផ្ដល់ឲ្យកម្ពុជាក្រោមគម្រោងពាណិជ្ជកម្ម EBA ដោយសារការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ នៃគោលការណ៍សិទ្ធិមនុស្ស។ ការដកការអនុគ្រោះពន្ធនិងការជំនួសរបស់ពួកគេជាមួយនឹងពន្ធស្តង់ដាររបស់សហភាពអឺរ៉ុប (ប្រទេសដែលអនុគ្រោះដល់ MFN) នឹងប៉ះពាល់ដល់ផលិតផលសម្លៀកបំពាក់និងស្បែកជើងផលិតផលដំណើរកំសាន្ត

---

[17] ក្រសួងពាណិជ្ជកម្ម, *របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០១៩ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២០*

[18] CDC. *Generalized System of Preferences (GSP).*

[19] European Commission. *Everything But Arms (EBA).*

និងស្ករ។ ការដកនេះ មានចំនួនប្រមាណមួយភាគប្រាំឬ ១ ពាន់លានអឺរ៉ូនៃការនាំចេញប្រចាំឆ្នាំរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប។[20]

### ២.១.៥ ការវិនិយោគផ្ទាល់ពីបរទេស

លំហូរ FDI មកកម្ពុជាបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដោយសារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចស្ថិរភាពនយោបាយកំណើនសេដ្ឋកិច្ចក្នុងតំបន់និងទីផ្សារវិនិយោគបើកចំហរ។ យោងតាមរបាយការណ៍វិនិយោគពិភពលោកឆ្នាំ ២០២០ របស់ UNCTAD បានបង្ហាញថាកម្ពុជាបានកត់ត្រាការវិនិយោគផ្ទាល់ពីបរទេសខ្ពស់បំផុតក្នុងឆ្នាំ ២០១៩ គឺ ៣,៧ ពាន់លានដុល្លារអាមេរិក (កើនឡើង ១៦% បើប្រៀបធៀបនឹង ៣,២ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៨) ដែលភាគច្រើនដោយសារតែការវិនិយោគរឹងមាំក្នុងវិស័យផលិតកម្មនិងសេវាកម្ម។ ភាគហ៊ុនវិនិយោគផ្ទាល់ពីបរទេសសរុបមានចំនួន ៣៨ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩។ បណ្តាប្រទេសវិនិយោគសំខាន់គឺប្រទេសចិន (វិនិយោគផ្ទាល់ពីបរទេសចិនលើសពីប្រភព FDI ផ្សេងទៀតទាំងអស់ដែលរួមបញ្ចូលគ្នា) ជប៉ុន ហុងកុង អាមេរិក ហូល្លង់និងបណ្តាប្រទេសអាស៊ានផ្សេងទៀត។

ឧស្សាហកម្មសំណង់ទាក់ទាញវិនិយោគិនបរទេសច្រើនជាងគេ បន្ទាប់មកគឺហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម (វិស័យវាយនភ័ណ្ឌ) កសិកម្មនិងទេសចរណ៍។ យោងតាមតួលេខចុងក្រោយរបស់ធនាគារកម្ពុជាក្នុងឆ្នាំ ២០១៩ លំហូរចូលនៃ FDI បានកើនឡើង ១២ ភាគរយដែលស្មើនឹង ៣,៥ ពាន់លានដុល្លារអាមេរិកដែលក្នុងនោះ ២,៣ ពាន់លានដុល្លារផ្តោតលើវិស័យហិរញ្ញវត្ថុ។ ជាថ្មីម្តងទៀត ប្រទេសចិនបានធ្វើការវិនិយោគជិតពាក់កណ្តាល (៤៣%) នៃការវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជា បន្ទាប់មកគឺកូរ៉េខាងត្បូង (១១%) វៀតណាម (៧%) ជប៉ុននិងសិង្ហបុរី (៦%) និង (៣៣%) មកពីប្រទេសដទៃទៀត[21]។

ជាទូទៅប្រទេសកម្ពុជាមានរបបវិនិយោគបរទេសបើកចំហនិងសេរី។ ដើម្បីសម្រួលដល់ការវិនិយោគបរទេសប្រទេសកម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) ដែលផ្តល់ឲ្យក្រុមហ៊ុននូវលទ្ធភាពទទួលបានដីហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្សេងៗទៀត ដើម្បីសម្រួលដល់ការរៀបចំនិងប្រតិបត្តិការអាជីវកម្ម។ យោងតាមក្រសួងការបរទេសសហរដ្ឋអាមេរិកក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញតែ

[20] European Commission. *Trade/Human Rights: Commission decides to partially withdraw Cambodia's preferential access to the EU market.*

[21] ធនាគារជាតិនៃកម្ពុជា, *Macroeconomic and Banking Sector Development in 2018 and Outlook for 2019.* (ភ្នំពេញ, ២០១៨)

ម្នាក់ឯងបានទាក់ទាញក្រុមហ៊ុនអាមេរិកដូចជាកូកា - កូឡា (ដែលវិនិយោគតែ ១០០ លានដុល្លារអាមេរិក)។ ទោះយ៉ាងណាប្រព័ន្ធច្បាប់របស់ប្រទេសនេះ ខ្វះតម្លាភាពការផ្គត់ផ្គង់ថាមពលនិងបញ្ហាដឹកជញ្ជូននៅតែជាឧបសគ្គគួរឲ្យកត់សម្គាល់ចំពោះការវិនិយោគអន្តរជាតិ។ អំពើពុករលួយ កង្វះកម្លាំងពលកម្មជំនាញ ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ និងថ្លៃថាមពលខ្ពស់ ក៏រួមចំណែកធ្វើឲ្យរាំងស្ទះដល់ការវិនិយោគផងដែរ។ ធនាគារពិភពលោកបន្តផ្តោតការយកចិត្តទុកដាក់លើបរិយាកាសធុរកិច្ចមិនល្អរបស់កម្ពុជានៅក្នុងរបាយការណ៍ធុរកិច្ចធ្វើឆ្នាំ ២០២០ របស់ខ្លួនដោយចាត់ចំណាត់ថ្នាក់ប្រទេសលេខ ១៤៤ ក្នុងចំណោម ១៩០ ប្រទេស (ធ្លាក់ចុះ ៦ ចំណុចបើប្រៀបធៀបនឹងឆ្នាំមុន)[22]។

**តារាងទី ២.១ ៖ ការវិនិយោគផ្ទាល់ពីបរទេសមកក្នុងកម្ពុជា**

| Foreign Direct Investment | 2017 | 2018 | 2019 |
|---|---|---|---|
| **FDI Inward Flow** *(million USD)* | 2,786 | 3,208 | 3,706 |
| **FDI Stock** *(million USD)* | 27,048.6 | 30,369.9 | 34,030.3 |
| **Number of Greenfield Investments*** ** | 39.0 | 51.0 | 19.0 |
| **Value of Greenfield Investments (million USD)** | 1,965 | 3,004 | 988 |

## ២.២ ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា

### ២.២.១ លក្ខណៈទូទៅនៃសេដ្ឋកិច្ចកម្ពុជា

ប្រទេសកម្ពុជាត្រូវបានគេដឹងថាជាប្រទេសដែលបានអនុវត្តន៍នៅប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីជាផ្លូវការតាំងពីឆ្នាំ ១៩៩៣ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ កម្ពុជាបានបើកឲ្យមានកម្មសិទ្ធិឯកជននិងធ្វើឯកជនភាវូបនីយកម្ម (បង្វែររបស់រដ្ឋជារបស់ឯកជន ) សហគ្រាសជាច្រើនឲ្យឯកជនកាន់កាប់វិញ ។ ទន្ទឹមគ្នានោះរដ្ឋអនុញ្ញាតឲ្យមានការធ្វើពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងការវិនិយោគទុនក្រៅប្រទេសផងដែរ។ ប្រទេសកម្ពុជាត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឲ្យហៅសនាមថា "ខ្លាសេដ្ឋកិច្ចថ្មីនៃអាស៊ី" ដោយសារប្រទេសអាស៊ីអាគ្នេយ៍មួយនេះ សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ថេរ និងលឿនរហ័ស ក្នុងរយៈពេលជាច្រើនឆ្នាំចុងក្រោយនេះ។ ទន្ទឹមនិងនេះកម្ពុជាមានវិស័យសំខាន់ៗចំនួន ៣ ដែលកំពុងតែរុញច្រានកំណើនសេដ្ឋកិច្ចកម្ពុជា

[22] https://santandertrade.com/en/portal/establish-overseas/cambodia/investing-3

ឲ្យក្លាយជា "កូនខ្លាសេដ្ឋកិច្ច" នៅក្នុងតំបន់អាស៊ាន។ វិស័យសំខាន់ៗដែលជាឆ្អឹងកងសេដ្ឋកិច្ចទាំងបីនោះមានដូចជា៖

- វិស័យឧស្សាហកម្ម
- វិស័យកសិកម្ម
- វិស័យសេវាកម្ម

ក្រៅពីវិស័យទាំង៣ខាងលើ ក៏នៅមានវិស័យសំខាន់ៗមួយចំនួនទៀតដែលជាធាតុផ្សំយ៉ាងសំខាន់ក្នុងការជំរុញឲ្យកម្ពុជារឹងមាំក្នុងការឈានទៅរកកំណើនសេដ្ឋកិច្ចខ្លាំងក្លានៅក្នុងតំបន់[23]។

## ២.២.២ វិស័យឧស្សាហកម្ម

ប្រទេសកម្ពុជាមានទីតាំងជាយុទ្ធសាស្ត្រនៅចំកណ្ដាលបេះដូងនៃអាស៊ីអាគ្នេយ៍។ ប្រទេសនេះ មានព្រំប្រទល់ជាប់ប្រទេសថៃ ប្រទេសលាវ និងប្រទេសវៀតណាម ហើយមានឈូងសមុទ្រថៃនៅខាងត្បូងឆៀងខាងលិច។ ប្រទេសនេះ មានប្រជាប្រិយភាពសម្រាប់ការផ្តល់មូលដ្ឋានផលិតកម្មដែលមានតម្លៃទាបសម្រាប់ឧស្សាហកម្មជាច្រើន។ ក្នុងចំណោមគុណសម្បត្តិជាច្រើនដែលប្រទេសនេះផ្តល់ជូនវិនិយោគិន គឺការចូលទៅកាន់ទីផ្សារធំ ៗ និងអភិវឌ្ឍន៍មួយចំនួនដែលមានសេដ្ឋកិច្ចមានស្ថេរភាព និងការលើកទឹកចិត្តរបស់រដ្ឋាភិបាលជាច្រើន។

លើសពីនេះទៀតមានតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនដែលត្រូវបានបង្កើតឡើងផ្ដាច់មុខដើម្បីជំរុញផលិតកម្មនៅទូទាំងប្រទេស។ បើនិយាយអំពីវិស័យឧស្សាហកម្មនៅកម្ពុជា (លើកលែង ឧស្សាហកម្មនិស្សារណកម្ម និងការរុករករ៉ែ) ភាគច្រើនសំដៅលើ វិស័យកាត់ដេរ កសិកម្ម សំណង់ និងទេសចរណ៍។ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទិសដៅក្នុងការប្រែក្លាយប្រទេសកម្ពុជា ឲ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ និងមានចំណូលកម្រិតខ្ពស់ក្នុងឆ្នាំ ២០៥០ ដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨។ ទិសដៅនេះ បញ្ជាក់ពីតួនាទីនៃវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម ដែលជាកត្តាជំរុញដ៏សំខាន់ចំពោះកំណើននាពេលអនាគត។ កាលពីខែមីនា ឆ្នាំ២០១៥ រដ្ឋាភិបាល បានរៀបចំនិងអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មដែលជាមគ្គុទេសក៍មួយ ដើម្បីផ្តល់នូវដំណោះស្រាយជាលក្ខណៈប្រព័ន្ធ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មឲ្យមានភាពប្រកួតប្រជែងនៅក្នុងប្រទេសកម្ពុជា។ វិស័យឧស្សាហកម្មចំបងៗ រួមមាន វិស័យកាត់ដេរ វិស័យសិប្បកម្មកែច្នៃម្ហូបអាហារ និងភេស

[23] https://www.kfa.com.kh/detailnews.php?id=19

ជ្ជៈ វិស័យសំណង់ វិស័យអចលនទ្រព្យ វិស័យទេសចរណ៍ ព្រមទាំងវិស័យរុករករ៉ែ និងការរុករកផ្សេងៗទៀតដែលកំពុងកើតមាន។[24]

ឧស្សាហកម្មកាត់ដេរនៅកម្ពុជាភាគច្រើនផ្តោតសំខាន់លើការនាំចេញនិងរួមបញ្ចូលយ៉ាងខ្លាំងទៅក្នុងបណ្តាញផ្គត់ផ្គង់ពិភពលោក។ សហភាពអឺរ៉ុប (EU) តំណាងឲ្យទីផ្សារធំបំផុតសម្រាប់ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាដែលស្មើនឹងប្រមាណ ៤០ភាគរយនៃផលិតកម្មសរុបបន្ទាប់មកសហរដ្ឋអាមេរិក (៣០ ភាគរយ) កាណាដា (៩ភាគរយ) និងជប៉ុន (៤ភាគរយ)។ ក្រុមហ៊ុនជាច្រើននៅក្នុងប្រទេសនេះប្រតិបត្តិការជាក្រុមហ៊ុនផលិតកិច្ចសន្យាសម្រាប់យីហោពហុជាតិធំៗ ដូចជា Adidas, Gap, H&M, Marks & Spencer និង Uniqlo។

នៅដើមទសវត្សឆ្នាំ ១៩៩០ រដ្ឋាភិបាលកម្ពុជាបានចាត់វិធានការផ្សេងៗដើម្បីជំរុញការប្រកួតប្រជែងឧស្សាហកម្មនៅក្នុងទីផ្សារអន្តរជាតិដែលជំរុញឲ្យវិនិយោគិនបរទេសដឹកនាំការយកចិត្តទុកដាក់របស់ខ្លួនមកប្រទេសនេះ។ លើសពីនេះទៀត ការអភិវឌ្ឍឧស្សាហកម្មរបស់ប្រទេសនេះត្រូវបានគាំទ្រដោយ Multi-Fiber Arrangements (MFA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះដទៃទៀតដែលត្រូវបានអនុវត្តដោយប្រទេសអភិវឌ្ឍន៍ដូចជាសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប។ ២ទសវត្សរ៍ក្រោយមក ឧស្សាហកម្មកាត់ដេរនៅតែបន្តជំរុញសេដ្ឋកិច្ចកម្ពុជាតាមរយៈ ការអភិវឌ្ឍន៍មូលធនមនុស្ស ការបង្កើតការងារ និងការវិនិយោគផ្ទាល់ពីបរទេស (FDI) ។ បច្ចុប្បន្ននេះបុគ្គលិកឧស្សាហកម្មនេះមានចំនួនជាង ៦០ ម៉ឺននាក់ដែលធ្វើឲ្យវិស័យនេះក្លាយជានិយោជកធំជាងគេបំផុតនៅក្នុងប្រទេស។ លើសពីនេះទៀត ឧស្សាហកម្មកាត់ដេរមានចំនួន ១៦ ភាគរយនៃផលិតផលក្នុងស្រុកសរុបនិង ៨០ ភាគរយនៃប្រាក់ចំណូលនាំចេញរបស់ប្រទេសកម្ពុជាហើយនៅឆ្នាំ ២០១៦ ចំនួនរោងចក្រកាត់ដេរនៅទូទាំងប្រទេសមានចំនួន ៥៨៩ រោងចក្រ[25]។

### ២.២.៣ វិស័យកសិកម្ម[26]

ចំនួនប្រជាជនរបស់ប្រទេសកម្ពុជា កំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស (១,៦% ជារៀងរាល់ឆ្នាំ) មានន័យថាទីផ្សារក្នុងស្រុករបស់ខ្លួនកំពុងតែរីកលូតលាស់ជាបន្តបន្ទាប់។ ដូចគ្នានេះដែរ ចំណែកអ្នករស់នៅតាមទីប្រជុំជនក៏កំពុងកើនឡើងផងដែរទោះបីជាប្រជាជនកម្ពុជាភាគច្រើននៅតែរស់នៅតាមទីជនបទដែលវិស័យកសិកម្មនៅតែផ្តល់ការងារ ៤២% នៃកម្លាំងពលកម្មសរុបរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១៧ ទោះបីតំណាងស្មើនឹង ២៦,៧% នៃផលិតផលក្នុងស្រុកសរុបរបស់ខ្លួនក៏ដោយ។

---

24 https://opendevelopmentcambodia.net/km/topics/industries/

25 https://www.aseanbriefing.com/news/cambodias-garment-manufacturing-industry/

26 file:///C:/Users/DARA%20COMPUTER/Downloads/Agriculture+in+Cambodia%20(1).pdf

លក្ខណៈភូមិសាស្ត្ររបស់ប្រទេសកម្ពុជាមួយផ្នែកពន្យល់ពីតួនាទីសំខាន់នៃកសិកម្ម។ ជាការពិតស្ទួល នៃទឹកដីរបស់ប្រទេសដែលភាគច្រើននៃប្រជាជនប្រមូលផ្តុំត្រូវបានកំណត់ដោយដីទំនាបនិងភ្នំដែលជាកន្លែងទឹកសាប (ឧទាហរណ៍ ទន្លេបឹងប្រភពក្រោមដី) មានច្រើន។ អាកាសធាតុនៅប្រទេសកម្ពុជាក៏អំណោយផលផងដែរ ប្រទេសទទួលបានអត្ថប្រយោជន៍ពីរដូវវស្សា (ចាប់ពីខែឧសភាដល់ខែតុលា) ដែលមានទំនាក់ទំនងជាមួយភ្លៀងធ្លាក់ខ្លាំងហើយសីតុណ្ហភាពនៅតែខ្ពស់ពេញមួយឆ្នាំ។ អំណោយផលធម្មជាតិទាំងនេះគឺអំណោយផលខ្លាំងសម្រាប់ការដាំដុះស្រូវដែលតំណាងឲ្យ ៦៨% នៃផ្ទៃដីដាំដុះទាំងអស់ក្នុងឆ្នាំ ២០១៣ ប៉ុន្តែក៏មានដំណាំជាច្រើនទៀតរួមមានពោតដំឡូងមីស្វាយនិងកៅស៊ូ។

ទោះយ៉ាងណាក៏ដោយបញ្ហាប្រឈមមួយចំនួនឈរលើផ្លូវនៃប្រទេសកម្ពុជាដើម្បីសម្រេចបាននូវសក្តានុពលផលិតកម្មកសិកម្មរបស់ខ្លួន។ ប្រទេសនេះនៅទាបជាងសមភាគីក្នុងតំបន់ទាក់ទងនឹងផលិតភាពដីធ្លីដោយសារការវិនិយោគការបណ្តុះបណ្តាល និងស្តង់ដារគុណភាពនៅតែមានកំរិតទាបនៅឡើយ។ ជាលទ្ធផលកំណើនក្នុងវិស័យកសិកម្មបានថយចុះមកប្រមាណមួយភាគរយជារៀងរាល់ឆ្នាំក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ ទោះយ៉ាងណានិន្នាការដូចជាការធ្វើពិពិធកម្មដំណាំមេកានិច ប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ធនធានដែលបានជ្រើសរើសការធ្វើពាណិជ្ជកម្មនិងការអភិវឌ្ឍឧស្សាហកម្មកែច្នៃកំពុងកើនឡើងនៅក្នុងប្រទេសកម្ពុជាហើយអាចផ្តល់នូវឱកាសវិនិយោគប្រកបដោយផ្លែផ្កាសម្រាប់វិនិយោគិនដែលមានបំណងនាំមកនូវដើមទុនជំនាញ និងការអនុវត្តល្អបំផុតដល់កម្ពុជា។

- **ស្រូវ**

ស្រូវគឺជាដំណាំសំខាន់របស់ប្រទេសកម្ពុជាដែលមានផលិតកម្មសរុបចំនួន ៩,៩៥លានតោនក្នុងឆ្នាំ ២០១៦ ។ ប្រទេសកម្ពុជា បាននាំចេញអង្ករចំនួន ៦៣៥ ៦៧៩ តោនក្នុងឆ្នាំ ២០១៧។ ពូជដែលត្រូវបាននាំចេញជាធម្មតាមានគុណភាពខ្ពស់ដូចដែលបានបង្ហាញដោយពានរង្វាន់ "អង្ករល្អបំផុតរបស់ពិភពលោក"។ កំណើននៃការនាំចេញអង្ករ ត្រូវបានផ្តល់អាទិភាពដោយរដ្ឋាភិបាលដូចដែលបានបង្ហាញដោយកិច្ចព្រមព្រៀងជាច្រើនជាមួយប្រទេសដៃគូដែលអនុញ្ញាតឲ្យកម្ពុជាធ្វើពិពិធកម្មដៃគូពាណិជ្ជកម្មរបស់ខ្លួនដល់គោលដៅចំនួន ៦៣ ក្នុងឆ្នាំ ២០១៧។ ផលិតកម្មរបស់ប្រទេសកម្ពុជាត្រូវបានបែងចែករវាង ស្រូវវស្សាដែលកំពុងលូតលាស់នៅរដូវវស្សានិងតំណាងឲ្យ ៨០% នៃទិន្នផលសរុបនិងដំណាំរដូវប្រាំងដែលត្រូវការបច្ចេកទេសធារាសាស្ត្រតែផ្តល់ទិន្នផលខ្ពស់ជាង។ រោងម៉ាស៊ីនកិនស្រូវ ផ្តល់សក្តានុពលគួរឲ្យចាប់អារម្មណ៍សម្រាប់ការអភិវឌ្ឍព្រោះថាប្រទេសនេះខ្វះសមត្ថភាពក្នុងការកែច្នៃផលិតផលក្នុងស្រុករបស់ខ្លួន។ ដូច្នេះផលិតកម្មរបស់ប្រទេសភាគច្រើនបច្ចុប្បន្នត្រូវបាននាំចេញទៅប្រទេសជិតខាងមុនពេលនាំចេញម្តងទៀត។

- **សាកវប្បកម្ម**

ក្រៅពីស្រូវប្រទេសកម្ពុជាផលិតដំណាំជាច្រើនប្រភេទដែលជាធម្មតានៃប្រទេសតំបន់ត្រូពិក។ កៅស៊ូ ដំឡូងមីនិងផ្លែឈើកម្រដែលបច្ចុប្បន្នស្ថិតក្នុងចំណោមទំនិញនាំចេញដែលពេញនិយមបំផុត។ ដោយសារ អំណោយទានធម្មជាតិរបស់ខ្លួនប្រទេសកម្ពុជា មានសក្តានុពលខ្ពស់ក្នុងការផលិតផលិតផលដែលមានគុណ ភាពខ្ពស់។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាត្រូវបានការពារពីការប្រើប្រាស់សារធាតុគីមីហួសកំរិតរហូតមក ដល់ពេលនេះ។ ជាមួយនឹងការខិតខំប្រឹងប្រែងកាន់តែខ្លាំងឡើងដើម្បីពង្រឹងបទដ្ឋាននិងបទដ្ឋានតឹងរឹងប្រទេស កម្ពុជាគួរតែអាចទទួលបានចំណែកកាន់តែច្រើនឡើងនៃទីផ្សារអន្តរជាតិសម្រាប់ដំណាំធំៗ ។ ទិន្នផលដំណាំ របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនិងដំណាំឧស្សាហកម្មកំពុងកើនឡើងលឿនជាងស្រូវ។ ដំណាំរួមផ្សំទទួលបានការ រីកចំរើន ៤០០%នៃផលិតកម្ម ក្នុងចន្លោះឆ្នាំ២០០៦និងឆ្នាំ២០១៥។ បន្ថែមពីលើការផ្តល់ប្រភពចំណូលជំនួស ការកើនឡើងនៃក្រុមហ៊ុនបុត្រសម្ព័ន្ធនិងដំណាំឧស្សាហកម្មផ្តល់ប្រាក់ចំណេញខ្ពស់ដល់អ្នកផលិត។ ដើម្បីគាំ ទ្រដល់ការផ្លាស់ប្តូរនេះកម្មវិធីជាច្រើនជួយកសិករដោយផ្តល់ឲ្យពួកគេនូវព័ត៌មានទីផ្សារការបណ្តុះបណ្តាលនិង បច្ចេកវិទ្យាក៏ដូចជាជម្រើសហិរញ្ញប្បទាន។ ការសហការជាមួយគម្រោងបែបនេះអាចផ្តល់នូវយន្តការចូលទីផ្សារ សម្រាប់អាជីវកម្មរបស់ប្រទេសហូឡង់ដែលមានគោលដៅផ្គត់ផ្គង់កសិករកម្ពុជានូវធនធានកសិកម្ម។

ផលិតផលបែបនេះត្រូវបានលើកលែងជាធម្មតាពីពន្ធនាំចូលហើយការវិនិយោគនៅក្នុងវិស័យនេះមាន សិទ្ធិទទួលបានការលើកទឹកចិត្តផ្សេងៗ។ ដូច្នេះដោយផ្តល់នូវជំនាញរបស់ក្រុមហ៊ុនហូឡង់ដំណោះស្រាយ ប្រព័ន្ធធារាសាស្ត្រគ្រឿងម៉ាស៊ីនកសិកម្មការចែកចាយគ្រាប់ពូជនិងជីអាចត្រូវបានគេចាត់ទុកថាជាឱកាសពាក់ ព័ន្ធ។ ចុងក្រោយ ប្រទេសកម្ពុជាក៏ខ្វះឧស្សាហកម្មកែច្នៃម្ហូបអាហារដែលមានការអភិវឌ្ឍផងដែរពោលគឺមានតែ ១០ ភាគរយនៃទំនិញកសិកម្មរបស់ប្រទេសកម្ពុជាត្រូវបានដំណើរការ។ ដូចគ្នានេះដែរការនាំចេញផលិតផល កសិកម្មរបស់កម្ពុជាភាគច្រើនជាផលិតផលឆៅ (គ្រាប់ស្វាយចន្ទីស្វាយ កៅស៊ូ និងដំឡូងមី) ឆ្ពោះទៅប្រទេស ថៃនិងវៀតណាមដែលជាកន្លែងកែច្នៃ។ លទ្ធផលនេះ ធ្វើឲ្យបាត់បង់សក្តានុពលបន្ថែមតម្លៃសម្រាប់ប្រទេសកម្ពុ ជា។ ឧស្សាហកម្មក្នុងស្រុកសម្រាប់ផលិតផលដូចជាម្សៅដំឡូងផលិតផលកៅស៊ូឬផ្លែឈើកែច្នៃនៅតែមិនទាន់ ចាប់ផ្តើមនៅឡើយ ប៉ុន្តែនៅតែបើកចំហសម្រាប់វិនិយោគិនដែលបណ្តាក់ទុនហើយនៅតែជាទីផ្សារដែលមិន ទាន់បានអនុវត្ត។

- **បសុសត្វនិងជលផល**

ការកើនឡើងនូវជីវភាពរស់នៅរួមជាមួយនឹងការធ្វើពិពិធកម្មចំណីអាហារក្នុងគ្រួសារកាន់តែច្រើន បាន ធ្វើឲ្យតម្រូវការសត្វចិញ្ចឹមនិងសាច់កើនឡើង (២៨០.០០០ តោនក្នុងឆ្នាំ ២០១៦) ។ នេះខ្ពស់ជាងកម្រិតនៃការ

ផ្គត់ផ្គង់ក្នុងស្រុកដែលបណ្តាលឲ្យការនាំចូលមានតម្លៃ ១០០ លានដុល្លារសម្រាប់ឆ្នាំ ២០១៦ ។ វិស័យជលផលគ្របដណ្តប់លើ ការនេសាទទឹកសាប ការនេសាទតាមសមុទ្រ និងវារីវប្បកម្មដែលទាំងអស់នេះមាននៅក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីការអភិវឌ្ឍនេះវាអាចមានលទ្ធភាពសម្រាប់ក្រុមហ៊ុនដើម្បីកំណត់គោលដៅវារីវប្បកម្មកម្ពុជាដែលជាទីផ្សារសក្តានុពលសម្រាប់គ្រាប់ពូជត្រីនិងចំណី ។

### ២.២.៤ វិស័យសេវាកម្ម

កម្ពុជា ជាប្រទេសមួយដែលគេបានស្រាវជ្រាវឃើញថា វិស័យសេវាកម្ម ដែលទាក់ទងច្រើនទៅនឹងវិស័យទេសចរណ៍ ជាកត្តាលិករមួយដែលជម្រុញកម្ពុជាមានលំហូរសេដ្ឋកិច្ចបានប្រមាណជា ៤០ភាគរយ នៃផលិតផលក្នុងស្រុកសរុប នេះបើតាមធនាគារអភិវឌ្ឍន៍អាស៊ីបានលើកឡើង។ របាយការណ៍របស់ ADB បានរកឃើញថា វិស័យសេវាកម្ម កំពុងតែមានសន្ទុះកំណើនទៅមុខ ប៉ុន្តែក៏ត្រូវចាំបាច់ដោះស្រាយឧបសគ្គជាច្រើនផ្សេងទៀត ដើម្បីឲ្យកម្ពុជាកាន់តែមានសក្តានុពលក្នុងការទាញយកប្រយោជន៍ពីវិស័យនេះផងដែរ។[27]

បើតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចបានបង្ហាញថា វិស័យសេវាកម្មបន្តកំណើនល្អប្រសើរក្នុងរង្វង់ ៧ភាគរយសម្រាប់ឆ្នាំ២០១៨នេះ និងឆ្នាំ២០១៩។ នៅក្នុងផ្នែកសេវាកម្ម វិស័យសំខាន់ៗទាំង៣ រួមមាន វិស័យទេសចរណ៍ ការលក់ដុំ-លក់រាយ ការដឹកជញ្ជូន និងទូរគមនាគមន៍ រួមជាមួយវិស័យអចលនទ្រព្យ ត្រូវបានរំពឹងទុកក្នុងកំណើនល្អប្រសើរ ក្នុងនោះវិស័យទេសចរណ៍នឹងបន្តងើបឡើង ក្នុងអត្រាកំណើន ៤,៥ភាគរយក្នុងឆ្នាំ២០១៨ ហើយនឹងបន្តងើបឡើងកាន់តែល្អថែមទៀតក្នុងរង្វង់ ៤,៧ភាគរយក្នុងឆ្នាំ២០១៩ ដោយសារកំណើនខ្ពស់នៃចំនួនភ្ញៀវទេសចរអន្តរជាតិ ជាពិសេសទេសចរណ៍នៅក្នុងតំបន់អាស៊ី រួមជាមួយការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ការលើកទឹកចិត្តជំរុញឲ្យមានការបើកជើងហោះហើរត្រង់ និងការដាក់ចេញនូវគោលនយោបាយនានា។ ចំណែកវិស័យលក់ដុំ-រាយត្រូវបានព្យាករថា នឹងមានកំណើនរឹងមាំក្នុងអត្រា ៧.២ភាគរយក្នុងឆ្នាំ២០១៨ និង៧,៣ភាគរយនៅក្នុងឆ្នាំ២០១៩ ដែលកំណើននេះនឹងឡើងខ្ពស់ជាងឆ្នាំ២០១៧ដែលមានត្រឹម ៦,៩ភាគរយ។ ជាក់ស្តែងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ការប្រើប្រាស់ទំនិញក្នុងស្រុកត្រូវបានវាយតម្លៃថា មានសម្ទុះខ្លាំង ហើយនិន្នាការនេះនឹងនៅតែបន្តទៅមុខទៀតព្រោះបច្ចុប្បន្នប្រជាជនមានប្រាក់ចំណូលមធ្យមបានកើនឡើង ដែលបានផ្លាស់ប្តូរឥរិយាបថក្នុងការចាយវាយមានច្រើនជាងមុនទៀតផង។

ដោយឡែកវិស័យអចលនទ្រព្យត្រូវបានរំពឹងថា នឹងនៅតែមានកំណើនតិចតួចក្នុងរង្វង់ ៨,៥ភាគរយក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ គឺមានការធ្លាក់ចុះបន្តិចបន្តួចបើប្រៀបធៀបទៅឆ្នាំ២០១៧។ ចំណែកវិស័យការ

[27] https://www.rfi.fr/km/adb-service-sector

ដឹកជញ្ជូននិងទូរគមនាគមន៍ក៏ត្រូវបានរំពឹងថា នឹងនៅបន្តមានកំណើនរឹងមាំក្នុងរង្វង់ ៧,៣ភាគរយក្នុងឆ្នាំ២០១៨ និង៧,៥ភាគរយនៅក្នុងឆ្នាំ២០១៩ បើប្រៀបធៀបទៅឆ្នាំ២០១៧ដែលស្ថិតក្នុងអត្រាកំណើន ៩,២ភាគរយ។ កំណើននៃវិស័យដឹកជញ្ជូន នឹងត្រូវជំរុញដោយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការបើកផ្លូវរថភ្លើងថ្មី ការពង្រីកព្រលានយន្តហោះ និងកំពង់ផែនានា ព្រមទាំងការធ្វើឲ្យប្រសើរឡើងនៃប្រព័ន្ធឡូជីស្ទិក (Logistic System) ដែលនឹងជួយប៉ះប៉ូវដល់កំណើនយឺតនៃការនាំចេញផលិតផលនានាផងដែរ[28]។

វិស័យសេវាកម្មបានជួយបង្កើនប្រាក់ចំណូលប្រមាណ ១,៧០៥ ពាន់លានដុល្លារដែលស្មើនឹងប្រមាណ ៣៩.៥ភាគរយនៃផលិតផលក្នុងស្រុកសរុប GDP ក្នុងឆ្នាំ២០១៨។ ក្នុងឆ្នាំ២០១៨ វិស័យនេះរួមចំណែកបង្កើតការងារដោយផ្ទាល់ប្រមាណ១២.៧ភាគរយ ដោយបានបង្កើតការងារចំនួន១ ១២១ ០០០ នៅក្នុងទេសចរណ៍និងការធ្វើដំណើរ។

[28] https://www.lareine.com.kh/news/eco-bussiness/22528/

# ជំពូកទី ៣៖ ដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

## ៣.១ ប្រវត្តិសង្ខេបនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

តំបន់សេដ្ឋកិច្ចពិសេស គឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើសមាហរណកម្មដែលកំពុងរីកចម្រើនរបស់កម្ពុជាទៅក្នុងខ្សែចង្វាក់ផលិតកម្មក្នុងតំបន់ និងពិភពលោក។ នៅឆ្នាំ ២០០៥ រដ្ឋាភិបាលកម្ពុជាបានអនុម័តអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ដោយបង្កើតក្រុមប្រឹក្សាភិបាលតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាជាមួយCDC។ បទពិសោធន៍របស់ប្រទេសចិនក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានគេប្រើជាគំរូដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា។ តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា មានចំនួនពីរប្រភេទគឺ តំបន់ឧស្សាហកម្មទូទៅ (Industrial zones) និងតំបន់កែច្នៃផលិតផលនាំចេញ (Export processing zones) ប៉ុន្តែការអនុវត្តជាក់ស្តែងរដ្ឋាភិបាល មិនបែងចែករវាងប្រភេទទាំងពីរនេះទេ។

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) គឺជាតំបន់សេដ្ឋកិច្ចពិសេសដែលរីកចម្រើនយ៉ាងលឿនបំផុតនៅក្នុងប្រទេសកម្ពុជា។ ចាប់ពីក្រុមហ៊ុនចំនួន ១៤ ដែលបានដំណើរការក្នុងឆ្នាំ ២០១១ វាមានកើនឡើងដល់ទៅ ៣៧ គិតត្រឹមពាក់កណ្តាលឆ្នាំ ២០១៣ ដែលកើនឡើង ១៦៤ ភាគរយក្នុងរយៈពេលតិចជាងពីរឆ្នាំ។ ហើយអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺ នៅឆ្នាំ ២០១៩ វាបន្តកើនឡើងរហូតដល់ ១០៥ ក្រុមហ៊ុន។ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញមានទីតាំងស្ថិតនៅខាងក្រៅរាជធានីភ្នំពេញបន្តិចដែលនៅជិតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (Phnom Penh SEZ Plc.) ជាអ្នកគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញដែលមានទំហំជាង ៣៥៧ ហិកតានិងមានក្រុមហ៊ុនអន្តរជាតិជាច្រើនមកពី ១៥ ប្រទេសផ្សេងគ្នាបានវិនិយោគនៅក្នុងតំបន់នោះ។ ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាក្នុងនាមជាអ្នកអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសពហុផលិតផល នៅថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០០៦ ។វិនិយោគិនធំៗនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ គឺមកពីប្រទេសជប៉ុន ប្រមាណ៥០ និងប្រទេសចិនចំនួន២៩ ប៉ុន្តែបើយើងប្រឡេកទៅមើលទំហំទឹកប្រាក់វិនិយោគវិញ ប្រទេសចិនស្ថិតនៅលំដាប់លេខ១ដែលមានតម្លៃប្រមាណ ២០៧លានដុល្លារ បន្ទាប់មកប្រទេសជប៉ុន ១៧៨លានដុល្លារ ហើយសហរដ្ឋអាមេរិក ១១២ លានដុល្លារ។ ផលិតកម្មនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញត្រូវបានកំណត់ទិសដៅទាំងសម្រាប់ការនាំចេញនិងទីផ្សារក្នុងស្រុក។ ក្រុមហ៊ុនផលិតដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រួមមានម៉ាកពីប្រទេសជប៉ុន ដូចជា Ajinomoto, Minebea, ប្រព័ន្ធខ្សែភ្លើង Sumitomo, និងផលិតផលទារក Combi ហើយក៏មានការវិនិយោគទៅលើឧស្សាហកម្មមួយចំនួនដូចជា ការផលិតគ្រឿងអេឡិចត្រូនិចធុនស្រាល (Denso)

ការកែច្នៃចំណីអាហារ (Vinamilk និង Betagro) និងប៉ូលាពេជ្រ (Laurelton diamonds)។ ជាងនេះទៅទៀតនោះ ក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោកដូចជា ក្រុមហ៊ុន Toyota, Yamaha, Tiffany និងCoca-Cola ក៏បានធ្វើការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញផងដែរ។

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) បានផ្តល់ជូននូវហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈទូលំទូលាយនិងស្តង់ដាខ្ពស់ដូចជា៖[29]

- ការផ្គត់ផ្គង់ថាមពល ២៤/៧
- ប្រព័ន្ធផ្គត់ផ្គង់ទឹក
- កន្លែងសម្អាតទឹកសំណល់
- ប្រព័ន្ធទូរគមនាគមន៍ដែលអាចទុកចិត្តបាននិងទំនើប

លើសពីនេះទៅទៀតនោះ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ក៏ផ្តល់ឲ្យនូវសេវាកម្មនៅនឹងកន្លែងផ្សេងទៀតដូចជា៖

- ការចុះឈ្មោះអាជីវកម្ម
- លិខិតអនុញ្ញាតនាំចូល / នាំចេញ
- ជំនួយក្នុងការស្វែងរកបុគ្គលិក
- ជំនួយគ្រប់គ្រងការងារដោយសហការជាមួយក្រសួងការងារ
- សន្តិសុខ ២៤ ម៉ោង
- ការប្រមូលនិងការចោលសំរាម
- អាហារដ្ឋាន និងកន្លែងស្នាក់នៅសម្រាប់កម្មករ
- ការពិគ្រោះយោបល់ផ្នែកច្បាប់ រដ្ឋបាល និងគណនេយ្យ

### ៣.២ គោលបំណងក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

គោលបំណងនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស គឺដើម្បីជួយអាជីវកម្មតាមរយៈការសម្របសម្រួលទៅលើឧបសគ្គនៃបទប្បញ្ញត្តិនិងច្បាប់ក្នុងការវិនិយោគ។ តំបន់សេដ្ឋកិច្ចពិសេស (SEZ) អាចត្រូវបានគេចាត់ទុកថាជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនិងជាអ្នកផ្តល់សេវាកម្ម ដើម្បីជាជំនួយក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាតាមរយៈ៖

- ទាក់ទាញលំហូរវិនិយោគបរទេសនិងក្នុងស្រុកយ៉ាងច្រើននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស

[29] https://ppsez.com/en/our-business/ppsez-overview

- ធ្វើសមាហរណកម្មក្រុមហ៊ុនក្នុងស្រុកទៅក្នុងខ្សែសង្វាក់ផលិតកម្មពិភពលោក
- លើកកម្ពស់កំណើនការនាំចេញ
- ធ្វើពិពិធកម្មសេដ្ឋកិច្ច
- បង្កើនសមត្ថភាពផលិតកម្ម
- បង្កើតការងារ

តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានបង្កើតឡើងដើម្បីចាប់ផ្តើមវិស័យឧស្សាហកម្ម និងដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យានិងការអភិវឌ្ឍជំនាញគ្រប់គ្រងទៅកាន់សេដ្ឋកិច្ចក្នុងស្រុក និងអាចចូលរួមចំណែកក្នុងការកែលម្អឲ្យប្រសើរឡើងនៅបរិយាកាសវិនិយោគ ការបន្ថយថ្លៃដើមប្រតិបត្តិការសម្រាប់សកម្មភាព FDI បង្កើនភាពងាយស្រួលក្នុងការធ្វើជំនួញនិងធ្វើឲ្យមានភាពងាយស្រួលនិងកាន់តែរហ័សពាក់ព័ន្ធនឹងដំណើរការនីតិវិធីរដ្ឋបាលផ្សេងៗ។ គោលដៅសំខាន់មួយទៀតនោះគឺ ការបង្កើតទំនាក់ទំនងរវាងតំបន់សេដ្ឋកិច្ចនិងឧស្សាហកម្មក្នុងស្រុកនិងកាត់បន្ថយនូវវិសមភាពសេដ្ឋកិច្ចក្នុងសង្គម។

## ៣.៣ លក្ខខ័ណ្ឌ និងនីតិវិធី

### ៣.៣.១ លក្ខខ័ណ្ឌក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស[30]

តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុញ្ញាតឲ្យបង្កើតឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅតាមតំបន់សមស្រប និងប្រកបដោយយុទ្ធសាស្ត្រតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាដោយអនុលោមតាមស្មារតីសម្រេចចិត្តរបស់របស់យន្តការច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា។ តំបន់សេដ្ឋកិច្ចពិសេស អាចផ្តួចផ្តើមបង្កើតឡើងដោយរដ្ឋ ឬឯកជន។

ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុលោមទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានដីចាប់ពី ៥០ ហិកតាឡើងទៅ ដោយត្រូវមានទីតាំងព្រំប្រទល់ភូមិសាស្ត្រច្បាស់លាស់
- មានរបងព័ទ្ធជុំវិញតំបន់ (សម្រាប់តំបន់ផលិតកែច្នៃនាំចេញ និងសម្រាប់ពាណិជ្ជកម្មសេរី និងគ្រប់ទីតាំងផ្ទាល់របស់អ្នកវិនិយោគក្នុងតំបន់នីមួយៗ)
- មានអាគារការិយាល័យចាត់ចែងការងារ ការិយាល័យរដ្ឋបាល មានប្រព័ន្ធផ្លូវគមនាគមន៍ ទូលាយតូច ធំ មានប្រព័ន្ធអគ្គីសនី បណ្តាញប្រែសណីយ៍ និងទូរគមនាគមន៍ និងមានប្រព័ន្ធការពារសុវត្ថិភាពទប់ទល់នឹងអគ្គីភ័យជាយថាហេតុ។ ផ្អែកទៅតាមស្ថានភាពលទ្ធភាពនិងស្ថានភាពជាក់ស្តែង តំបន់

[30] មាត្រា ៣នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

អាចមានដីបម្រុងទុកសម្រាប់មជ្ឈមណ្ឌល លំនៅដ្ឋានរបស់កម្មករ និយោជិក និងនិយោជក មានសួន លំហែកាយ មានគិលានដ្ឋាន សាលាបណ្តុះបណ្តាលមុខជំនាញ ស្ថានីយប្រេងឥន្ធនៈ ភោជនីយដ្ឋាន ចំណតយានយន្ត អាគារលក់ទំនិញឬផ្សារ ។ល។

- មានប្រព័ន្ធបង្ហូរទឹកសម្អុយ ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតសំណល់រាវ មានទីតាំងទុកដាក់សំណល់រឹងត្រឹមត្រូវ មានវិធានការណ៍ការពារបរិស្ថាន និងបណ្តាហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដទៃឬទៀតតាមស្ថានភាពជាក់ស្តែងតាមតម្រូវការ
- លក្ខណៈបច្ចេកទេស បទប្បញ្ញត្តិ និងបទដ្ឋានជាមូលដ្ឋាននានា បម្រើឲ្យការសាងសង់ កិច្ចការបរិស្ថាន និងកិច្ចការជំនាញផ្សេងៗទៀតសម្រាប់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស។ ជាមូលដ្ឋានខាងលើនេះ ត្រូវមានការកំណត់ណែនាំដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ចជំនាញ តាមរយៈការចងក្រងជាបទដ្ឋានទៅតាមច្បាប់ និងស្តង់ដាជាតិនិងអន្តរជាតិផ្អែកតាមភូមិសាស្ត្រ និងតំបន់ជាក់ស្តែងនីមួយៗ

### ៣.៣.២ នីតិវិធីក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស[31]

- អ្នកអភិវឌ្ឍន៍តំបន់ទាំងឡាយ ដែលមានបំណងចង់បណ្តាក់ទុនធ្វើការអភិវឌ្ឍន៍នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រូវធ្វើសំណើរគោលការណ៍អភិវឌ្ឍន៍នៅក្នុងតំបន់មកគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុនសិន។ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាមានភារកិច្ចធ្វើការសន្និដ្ឋានសំណើរហើយលើកយោបល់ លើកជូនកិច្ចប្រជុំច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា ដើម្បីធ្វើការសម្រេចផ្តល់គោលការណ៍ ឬបដិសេធគោលការណ៍សុំបង្កើតតំបន់។ អ្នកអភិវឌ្ឍន៍តំបន់ ត្រូវបង់ថ្លៃដាក់ពាក្យសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅពេលដាក់ពាក្យចំនួន ៧ ០០០ ០០០រៀលជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។
- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ត្រូវឆ្លើយតបអំពីលទ្ធផលវិជ្ជមាន ឬអវិជ្ជមានរបស់សំណើរក្នុងរយៈពេលយ៉ាងយូរ ២៨ថ្ងៃ នៃថ្ងៃធ្វើការជូនអ្នកអភិវឌ្ឍន៍វិញ។
- អ្នកអភិវឌ្ឍន៍តំបន់ ដែលបានទទួលគោលការណ៍ឲ្យអភិវឌ្ឍន៍ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាអាចមានរយៈពេល ១៨០ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធ្វើគម្រោងសិក្សាសមិទ្ធិផល លទ្ធភាពសេដ្ឋកិច្ចលម្អិត។ ឯកសារពាក់ព័ន្ធនានា ឬលិខិតបញ្ជាក់ផ្សេងៗទៀតដែលគណៈកម្មាធិការតំបន់

[31] មាត្រា ៣នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

សេដ្ឋកិច្ចពិសេសកម្ពុជា តម្រូវទៅតាមសំណូមពររបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ដោយតម្រូវការទាំងនោះត្រូវកំណត់ក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌជូនអ្នកអភិវឌ្ឍន៍តំបន់។

- ក្នុងរយៈពេលយ៉ាងយូរ ១០០ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលអ្នកអភិវឌ្ឍន៍តំបន់ដាក់គម្រោង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាត្រូវទទួលយកជំនួសឲ្យអ្នកអភិវឌ្ឍន៍តំបន់នូវការយល់ព្រម ការអនុញ្ញាតអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងបញ្ជីនានាពីក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចឬភ្នាក់ងារដែលមានការពាក់ព័ន្ធផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមានភារកិច្ចផ្ដល់ឯកសារទាំងនេះ ព្រមជាមួយគ្នានូវការចេញជូនវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដល់អ្នកអភិវឌ្ឍន៍តំបន់។
- ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងព្រំដែនខណ្ឌសីមារបស់តំបន់សេដ្ឋកិច្ចនីមួយៗ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ស្របពេលដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាផ្ដល់វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដល់អ្នកអភិវឌ្ឍន៍តំបន់។
- អ្នកអភិវឌ្ឍន៍តំបន់ ដែលមិនបានអនុវត្តគម្រោងយ៉ាងតិច ៣០ ភាគរយនៃទុនវិនិយោគសរុប ក្នុងរយៈពេល ៣៦៥ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានសិទ្ធដកហូតមកវិញនូវគោលការណ៍អភិវឌ្ឍន៍តំបន់ ការលើកទឹកចិត្តនានាដែលបានផ្ដល់ជូនតាមវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរកន្លងមក។

### ៣.៣.៣ នីតិវិធីចុះឈ្មោះគម្រោងវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស[32]

អ្នកវិនិយោគ ដែលចាប់ផ្ដើមសកម្មភាពផលិតកម្មឬសេវាកម្មនៅក្នុងវិស័យដែលត្រូវបានអនុញ្ញាតិដោយច្បាប់ពាក់ព័ន្ធនិងអនុក្រឹត្យនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបំពេញបែបបទដោយផ្អែកលើនីតិវិធីដោយរៀបចំរាល់ឯកសារដែលត្រូវការហើយដាក់ជូនទៅរដ្ឋបាលនៃតំបន់សេដ្ឋកិច្ចពិសេស។ រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសមានកាតព្វកិច្ចសំរេចលើការចុះឈ្មោះសំណើវិនិយោគដោយផ្អែកលើទាំងទិដ្ឋភាព ច្បាប់ រដ្ឋបាល និងមុខជំនាញ ដើម្បីទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ (FRC)។ ដំណើរការបែបនេះត្រូវតែអនុលោមតាមនីតិវិធីនៃការចុះឈ្មោះវិនិយោគដែលមានចែងក្នុងច្បាប់និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការវិនិយោគ។ រាល់ការលើកទឹកចិត្តវិនិយោគដែលបានផ្ដល់ជូនវិនិយោគិនតំបន់ ត្រូវសម្រេចដោយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសតាមរយៈយន្តការ" ច្រកចេញចូលតែមួយ" ដែលមានទីតាំងនៅលើទីតាំងនិងអនុលោម តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ។

[32] មាត្រា ៣នៃអនុក្រិត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

រាល់សំណើផ្សេងទៀតនៅក្នុងដំណើរការវិនិយោគរបស់អ្នកវិនិយោគ រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ត្រូវដើរតួនាទីជាអ្នកសម្របសម្រួល ដើម្បីដោះស្រាយបញ្ហារបស់អ្នកវិនិយោគជាមួយ ក្រសួងឬស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា យោងតាមមាត្រា ៣.៣ អនុក្រឹត្យតំបន់សេដ្ឋកិច្ចពិសេស។

## ៣.៤ គោលនយោបាយរដ្ឋាភិបាល

### ៣.៤.១ ការលើកទឹកចិត្តផ្នែកសារពើពន្ធ

#### ៣.៤.១.១ ពន្ធលើប្រាក់ចំណេញ

អ្នកអភិវឌ្ឍនិងវិនិយោគិន នឹងត្រូវបានទទួលបានការយកចិត្តទុកដាក់ និងលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាល ដោយតាមរយៈការដាក់ស្ថាប័នដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)។ ចំពោះ QIPs អ្នកវិនិយោគមានសិទ្ធិទទួលបានការលើកទឹកចិត្តវិនិយោគឬហៅម៉្យាងទៀតថាវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ ដោយពួកគេអាចជ្រើសរើសដើម្បីទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញឬប្រើការរំលោះពិសេស ហើយចំពោះការលើកលែងពន្ធលើប្រាក់ចំណេញគឺទទួលបានសរុបអតិបរមារហូតដល់ ៩ ឆ្នាំ[33]។ ការលើកទឹកចិត្តនេះស្របទៅនឹងមាត្រា ១៤ថ្មី វគ្គខណ្ឌទី១ នៃច្បាប់ស្តីពីការវិនិយោគនៅកម្ពុជាឆ្នាំ២០០១។

**តារាងទី ៣.១ ៖ ពន្ធលើប្រាក់ចំណេញ**

| Country | Tax holiday | Corporate income tax | Import Duty and other taxes | Others | Land use |
|---|---|---|---|---|---|
| Cambodia | Up to 9 years | Standard: 20% | Tax exemption: import of equipments, construction materials and production inputs | Custom duty exemption on the import of machinery, equipment for construction of public services infrastructure. | Lease(Up to 99 Years) |

#### ៣.៤.១.២ ពន្ធគយ និងអាករដទៃទៀត [34]

រដ្ឋាភិបាល បានផ្តល់ការអនុគ្រោះលើពន្ធគយនិងអាករដ៏ទៃទៀតទៅដល់វិនិយោគកិនដូចជា ការលើកទឹកចិត្តលើការនាំចូល សម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ធាតុចូលផលិតកម្ម ត្រូវសម្រេចផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់តាមសំណូមពរ និងគោលការណ៍នៃច្បាប់ ដោយសាមីអ្នកវិនិយោគ ក្នុងតំបន់នោះ ត្រូវរៀបចំបញ្ជីសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ធាតុចូលផលិតកម្មដែលត្រូវនាំចូល ទាំងនោះ ដាក់ជូនរដ្ឋ

[33] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, http://www.cambodiainvestment.gov.kh/investment-scheme/investment-incentives.html1

[34] អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, *តំបន់សេដ្ឋកិច្ចពិសេស.*

បាលតំបន់សេដ្ឋកិច្ចពិសេសពិនិត្យដែលនឹងត្រូវផ្តល់ជូននៅនឹងកន្លែង ហើយរដ្ឋបាល តំបន់សេដ្ឋកិច្ចពិសេស គ្រាន់តែរាយការណ៍ជូនមក គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងស្ថាប័នគ្រប់គ្រង ដើម្បីជ្រាបជាព័ត៌មានប៉ុណ្ណោះ។ ការអនុគ្រោះនេះមានន័យថារាល់ការបង់ពន្ធ និងអាករដ៏ទៃទៀតលើសម្ភារៈសម្រាប់បម្រើឲ្យគោលដៅខាងលើនេះ គឺបន្ទុករបស់រដ្ឋដោយរដ្ឋជាអ្នកធានាលើការចំណាយ។ ចំពោះសិទ្ធិដែលត្រូវបានទទួលការលើកទឹកចិត្តផ្នែកសារពើពន្ធនឹងសម្រេចជូនអ្នកវិនិយោគក្នុងតំបន់ នៅក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ដែលនឹងត្រូវចេញជូនអ្នកវិនិយោគក្នុងតំបន់ ស្របតាមច្បាប់ និងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

### ៣.៤.១.៣ អាករលើតំលៃបន្ថែម

បើតាមការកត់ត្រាតាមរយៈ កូនសៀវភៅពន្ធកម្ពុជាឆ្នាំ២០១៨ (Cambodian 2018 Tax Booklet) មានអត្រាអាករលើតម្លៃបន្ថែមចំនួនពីរ[35]៖

- 0%៖ អត្រានេះ អនុវត្តចំពោះការនាំចេញទំនិញ និងសេវាកម្មពីប្រទេសកម្ពុជា។ ការនាំចេញសេវាកម្មរួមមាន ការដឹកជញ្ជូនអ្នកដំណើរ ឬទំនិញអន្តរជាតិ ឬសេវាកម្មនានាដែលពាក់ព័ន្ធនឹងបញ្ហានេះ។ អត្រានេះ ក៏ត្រូវអនុវត្តចំពោះឧស្សាហកម្មទ្រទ្រង់ ឬអ្នកម៉ៅការរងដែលផ្គត់ផ្គង់ទំនិញនិងសេវាកម្មជាក់លាក់ដល់អ្នកនាំចេញ (ឧទាហរណ៍រោងចក្រវាយនភណ្ឌ) ត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យជាក់លាក់។ ការផ្គត់ផ្គង់ស្រូវក្នុងស្រុកនិងការនាំចេញអង្ករ ក៏ជាកម្មវត្ថុនៃអាករលើតម្លៃបន្ថែម 0% ដែរ។
- 10%៖ នេះគឺជាអត្រាស្តង់ដារ ហើយអនុវត្តចំពោះការផ្គត់ផ្គង់ផ្សេងទៀត។

យោងតាមមាត្រា៦.៣ នៃអនុក្រឹត្យ ស្តីពីតំបន់សេដ្ឋកិច្ចពិសេសអ្នកវិនិយោគក្នុងតំបន់ដែលទទួលបាននូវការលើកទឹកចិត្តចំពោះអាករលើតំលៃបន្ថែម តាមអត្រា0% ត្រូវបានធ្វើការកត់ត្រាទុកនូវប្រាក់ពន្ធដែលបានលើកលែងនេះសម្រាប់ការនាំចូលមួយលើកៗរបស់អ្នកវិនិយោគក្នុងតំបន់ ហើយតួលេខនេះនឹងត្រូវលុបចោលប្រសិនបើធាតុចេញផលិតកម្មត្រូវបាននាំចេញទៅវិញ។ ក្នុងករណីដែលធាតុចេញផលិតកម្មបានបង្វិលនាំចូលទៅទីផ្សារក្នុងស្រុក អ្នកវិនិយោគក្នុងតំបន់ត្រូវបង់ពន្ធសងមកវិញនៅអាករលើតម្លៃបន្ថែមនេះតាមចំនួនទឹកប្រាក់ដែលបានកត់ត្រាទុក ដោយប្រៀបធៀបនឹងចំនួនបរិមាណដែលនាំចេញ។ និយាយជារួម អាករលើតម្លៃបន្ថែម(វត្ថុធាតុដើម) និងត្រូវលុបចោលប្រសិនបើទំនិញដែលត្រូវបានផលិតដោយអ្នកវិនិយោគក្នុងតំបន់បាននាំចូលក្នុងទីផ្សារកម្ពុជា។

---

35 PWC. *Cambodia 2018 Tax Booklet*. (2018)

## ៣.៥ អត្ថប្រយោជន៍ដែលប្រទេសកម្ពុជាទទួលបានពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

### ៣.៥.១ លំហូរការវិនិយោគផ្ទាល់ពីបរទេស

ក្រោយពីតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើង យើងសង្កេតឃើញថាបណ្តាវិនិយោគផ្ទាល់ពីបរទេសមានចំនួនកើនឡើង ដែលជាកត្តាមួយជួយជំរុញសេដ្ឋកិច្ចជាតិផងដែរ។

រដ្ឋាភិបាលកម្ពុជាខិតខំធ្វើយ៉ាងណា ដើម្បីទាក់ទាញអ្នកវិនិយោគផ្ទាល់ពីបរទេសឲ្យកាន់តែច្រើនឡើងឲ្យមកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស ព្រោះអ្នកវិនិយោគកាន់តែច្រើនក្នុងតំបន់សេដ្ឋកិច្ចពិសេស ធ្វើឲ្យយើងទទួលបានផលប្រយោជន៍ជាច្រើនចំពោះប្រទេសនិងប្រជាជនដូចជា ទទួលបានធនធានហិរញ្ញវត្ថុ ជំនាញ ការងារ ចំណេះដឹងនៃការប្រើប្រាស់បច្ចេកទេសទំនើប បទពិសោធន៍ខាងសហគ្រិន ការកសាងសមត្ថភាពការងារដល់ពលរដ្ឋ នាពេលអនាគត។

បើយើងងាកមកមើលលំហូរ FDI មកកម្ពុជាបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដោយសារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចស្ថិរភាពនយោបាយកំណើនសេដ្ឋកិច្ចក្នុងតំបន់និងទីផ្សារវិនិយោគបើកចំហ។ យោងតាមរបាយការណ៍វិនិយោគពិភពលោកឆ្នាំ ២០២០ របស់ UNCTAD បានបង្ហាញថាកម្ពុជាបានកត់ត្រាការវិនិយោគផ្ទាល់ពីបរទេសខ្ពស់បំផុតក្នុងឆ្នាំ ២០១៩ គឺ ៣,៧ ពាន់លានដុល្លារអាមេរិក (កើនឡើង ១៦% បើប្រៀបធៀបនឹង ៣,២ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៨) ដែលភាគច្រើនដោយសារតែការវិនិយោគរឹងមាំក្នុងវិស័យផលិតកម្មនិងសេវាកម្ម។ ភាគហ៊ុនវិនិយោគផ្ទាល់ពីបរទេសសរុបមានចំនួន ៣៤ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩។

បណ្តាប្រទេសវិនិយោគសំខាន់គឺប្រទេសចិន (វិនិយោគផ្ទាល់ពីបរទេសចិនលើសពីប្រភព FDI ផ្សេងទៀតទាំងអស់ដែលរួមបញ្ចូលគ្នា) ជប៉ុន ហុងកុង អាមេរិក ហូល្លង់ និងបណ្តាប្រទេសអាស៊ានផ្សេងទៀត។ ឧស្សាហកម្មសំណង់ទាក់ទាញវិនិយោគិនបរទេសច្រើនជាងគេបន្ទាប់មកគឺហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម (វិស័យវាយនភណ្ឌ) កសិកម្មនិងទេសចរណ៍។

យោងតាមតួលេខចុងក្រោយរបស់ធនាគារជាតិនៃកម្ពុជាក្នុងឆ្នាំ ២០១៩ លំហូរចូលវិនិយោគផ្ទាល់ពីបរទេសបានកើនឡើង ១២ ភាគរយដល់ ៣,៥ ពាន់លានដុល្លារក្នុងនោះ ២,៣ ពាន់លានដុល្លារជាកន្លែងដែលសំដៅដល់វិស័យហិរញ្ញវត្ថុ។ ជាថ្មីម្តងទៀតប្រទេសចិនមានចំនួនជិតពាក់កណ្តាលនៃការវិនិយោគ (៤៣%) បន្ទាប់មកគឺកូរ៉េខាងត្បូង (១១%) វៀតណាម (៧%) ជប៉ុននិងសិង្ហបុរី (៦%) ។ [36]

[36] https://www.cpp.org.kh/details/175676

ដើម្បីសម្រួលដល់ការវិនិយោគបរទេស ប្រទេសកម្ពុជាក៏បានបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) ដែលផ្តល់ឲ្យក្រុមហ៊ុននូវលទ្ធភាពទទួលបាន ដី ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្សេងៗទៀត ដើម្បីសម្រួលដល់ការរៀបចំនិងប្រតិបត្តិការអាជីវកម្ម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញតែមួយបានទាក់ទាញក្រុមហ៊ុនអាមេរិកដូចជាកូកា - កូឡា (ដែលវិនិយោគតែ ១០០ លានដុល្លារអាមេរិក)។

### ៣.៥.២ ការបង្កើតការងារ

គិតត្រឹមឆ្នាំ ២០១៩ កម្ពុជាមានតំបន់សេដ្ឋកិច្ចពិសេសសរុបចំនួន ៥៤ យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ នៅឆ្នាំ ២០១៩ ការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេសរបស់កម្ពុជាមានចំនួន ២,៦៨៨ លានដុល្លារកើនឡើង ២៧ ភាគរយបើប្រៀបធៀបនឹងឆ្នាំ ២០១៨ ។ ជាពិសេសសម្រាប់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញដែលមានផ្ទៃដី ៣៥៣ ហិកតាមានក្រុមហ៊ុនវិនិយោគចំនួន ១០៥ ដែលផ្តល់ការងារចំនួន ២១,៨០០ សម្រាប់ប្រជាជនកម្ពុជា។ ការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញមានតម្លៃ ៥១៨ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩ ។

ម៉្យាងវិញទៀតនៅក្នុងតំបន់សេដ្ឋពិសេសភ្នំពេញការបង្កើតការងារសម្រាប់ប្រជាពលរដ្ឋកដែលមានជំនាញ និងអត់ជំនាញគឺតាមរយៈបីចំណុច[37]៖

ក. ការបង្កើតការងារដោយផ្ទាល់

ខ. ការបង្កើតការងារដោយប្រយោល

គ. ការបង្កើតការងារសម្រាប់ស្ត្រី

#### ៣.៥.២.១ ការបង្កើតការងារដោយផ្ទាល់

តំបន់សេដ្ឋកិច្ចពិសេសជាប្រភពសំខាន់ក្នុងការបង្កើតការងារសម្រាប់កម្មករកម្ពុជាទាំងមានជំនាញនិងទាំងគ្មានជំនាញ។ ជាទូទៅក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស រាជរដ្ឋាភិបាលតែងតែទាក់ទាញវិនិយោគិន ឲ្យសាងសង់នូវឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើនជាការបង្កើតការងារទាំងកម្មករមានជំនាញ និងគ្មានជំនាញ ដូច្នេះនៅពេលដែលតំបន់សេដ្ឋកិច្ចពិសេសកាន់តែលូតលាស់ នោះការងារកាន់តែសំបូរបែប។ លើសពីនេះទៅទៀតនៅក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេសទាមទារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជា ការកសាងប្រព័ន្ធផ្លូវ ទឹក អគ្គីសនី អាគារការិយាល័យ ប្រព័ន្ធចម្រោះទឹកកខ្វក់ និងសំណង់ផ្សេងៗ ដែលទាមទារនូវកម្លាំងពលកម្មដែលគ្មានជំនាញយ៉ាងច្រើន។

[37] http://www.cambodiainvestment.gov.kh/adbs-study-found-sezs-in-cambodia-attracted-foreign-investment-and-created-job.html

### ៣.៥.២.២ ការបង្កើតការងារដោយប្រយោល

ដំណើរការប្រតិបត្តិការក្នុងតំបន់សេដ្ឋកិច្ចពិសេស និងបង្កើតឱកាសការងារបន្ថែមទៀតដោយប្រយោលសម្រាប់ប្រជាពលរដ្ឋខ្មែរ ជាពិសេសទាក់ទងនឹងវិស័យសេដ្ឋកិច្ចរួមមាន ការដឹកជញ្ជូនទាំងផ្លូវគោក និងផ្លូវទឹក ទេសចរណ៍ និងបដិសណ្ឋារកិច្ច ទូរគមនាគម៍ ការលើកដាក់-ការខ្ចប់ទំនិញ អាកាសចរណ៍ស៊ីវិល ធនាគារនិងធនាវ៉ាប់រង។ ទាំងនេះនឹងបង្កើតការងារទាំងកម្មករមានជំនាញ និងគ្មានជំនាញ។ បន្ថែមពីនេះទៀត តំបន់សេដ្ឋកិច្ចពិសសេសនឹងមានឥទ្ធិពលលើការបង្កើតការងារដោយវិធី៣យ៉ាងដូចខាងក្រោម៖

- តំបន់សេដ្ឋកិច្ចពិសេស និងផ្តល់ឲ្យនូវការរកចំណូលតាមរយៈអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេសដែលជាការបង្កភាពងាយស្រួលក្នុងការផ្លាស់ប្តូររូបិយប័ណ្ណបរទេស និងជួយសម្រួលដល់វិនិយោគិនក្នុងការរកស៊ីព្រមទាំងជម្រុញសកម្មភាពសេដ្ឋកិច្ច។
- វាអាចបង្កើតសកម្មភាពសេដ្ឋកិច្ចនៅក្រៅតំបន់ តាមរយៈការបង្វែពីមូលនិធិវិនិយោគចូលទៅក្នុងអចលនទ្រព្យ និងការទិញវត្ថុធាតុដើម និងសេវាកម្មពីខាងក្រៅ។
- ការកើនឡើងនូវតម្រូវការសម្រាប់ទំនិញ និងសេវាកម្មផ្សេងៗដូចជា សុខភាព ការអប់រំ និងការដឹកជញ្ជូន បានបង្កើននៅប្រាក់ចំណូលបន្ថែមសម្រាប់ប្រជាពលរដ្ឋ។

### ៣.៥.២.៣ ការបង្កើតការងារសម្រាប់ស្ត្រី

នៅក្នុងដំណើរការងារនៃតំបន់សេដ្ឋកិច្ចពិសេស ស្ត្រីក៏បានចូលរួមចំណែកនៅក្នុងការងារនៅក្នុងតំបន់នេះដែរ។ ជាក់ស្តែងនិយោជក តែងតែចង់បានកម្មករជាស្ត្រីជាជាងបុរស ពីព្រោះស្ត្រីជាមនុស្សដែលមានចិត្តអំណត់និងការងារ តស៊ូក្នុងការងារ និងគោរពវិន័យការងារ ដែលសក្តិសមបម្រើការងារនៅក្នុងវិស័យសេដ្ឋកិច្ច និងផលិតកម្មទាំងមានជំនាញ និងគ្មានជំនាញ។ ជាងនេះទៅទៀត ស្ត្រីតែងតែមិនប្រើប្រាស់កម្លាំងរបស់ខ្លួនមកគាបសង្កត់ម្ចាស់រោងចក្រឲ្យតំឡើងប្រាក់បៀវត្ស និងលក្ខខណ្ឌការងារ។

### ៣.៥.៣ ការអភិវឌ្ឍន៍ជំនាញ

មានរបៀបផ្សេងៗគ្នាដែលតំបន់សេដ្ឋកិច្ចពិសេសអាចចូលរួមចំណែកជាវិជ្ជមានដល់ការបង្កើតមូលធនមនុស្ស ក៏ដូចជាការការអភិវឌ្ឍន៍ជំនាញដល់ប្រជាជនកម្ពុជាឲ្យប្រសើឡើង ដែលផលវិជ្ជមានទាំងនោះមានដូចខាងក្រោម៖

នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស នឹងមានការបង្កើននៅរោងចក្រ និងក្រុមហ៊ុនទាំងខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ។ ហេតុដូចច្នេះក្រុមហ៊ុនទាំងនេះ នឹងទាមទារនិយោជិកខ្មែរដែលមានជំនាញកាន់តែប្រសើរឡើង ជាហេតុដែលនាំឲ្យសហគ្រាសទាំងនេះមានការបណ្តុះបណ្តាលជំនាញបន្ថែមដល់និយោជិកក្នុងសហគ្រាស។

ការបណ្តុះបណ្តាលជំនាញបន្ថែមនេះហើយ គឺជាសកម្មភាពកម្រិតរឹងមាំដែលកម្លាំងពលកម្មក្នុងប្រទេសម្ចាស់ផ្ទះទទួលបានជំនាញពីក្រុមហ៊ុនតាមរយៈការបណ្តុះបណ្តាលនិងការរៀនសូត្រដោយធ្វើការងារ។ បុគ្គលិកដែលទទួលបានជំនាញនេះពួកគេអាចយកមកប្រើប្រាស់បាននៅថ្ងៃខាងមុខ ដោយអាចជួយដល់សេដ្ឋកិច្ចមួយកម្រឹតទៀត។ សរុបមកនិយោជិកកម្ពុជានឹងទទួលបាននូវជំនាញមួយដែលមានលក្ខណៈច្បាស់លាស់ និងប្រែក្លាយជាធនធានមនុស្សមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍកម្ពុជា។

មួយវិញទៀតសហគ្រាសទាំងឡាយក្នុងតំបន់សេដ្ឋកិច្ចពិសេស នឹងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអប់រំដើម្បីជាការឆ្លើយតបនឹងតម្រូវការក្នុងតំបន់។ ការបង្កើតជំនាញសម្រាប់កម្មករដែលគ្មានជំនាញក៏កើតមានផងដែរ តាមរយៈការបង្កើនសមត្ថភាពការងារ។ នេះអាចបង្កើនសុខមាលភាពរបស់កម្មករដែលគ្មានជំនាញដោយបង្កើនឱកាសការងារ សម្រាប់ពួកគេ ហើយក្រុមហ៊ុនក្នុងស្រុកអាចទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាលនេះដោយជួលកម្មករដែលធ្លាប់បម្រើការនៅក្នុងក្រុមហ៊ុន។[38]

### ៣.៥.៤ លំហូរនៃបច្ចេកវិទ្យា

តំបន់សេដ្ឋកិច្ចពិសេសនឹងធ្វើឲ្យមានប្រតិបត្តិការរវាង សហគ្រាសក្នុងស្រុក និងក្រុមហ៊ុនពហុជាតិដោយមានការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវវិស័យបច្ចេកវិទ្យា។ ជាធម្មតា នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសប្រាកដជាមានការវិនិយោគពីសហគ្រាសដែលមានបច្ចេកវិទ្យាជឿនលឿន ដូចជាឧស្សាហកម្មផលិតយានយន្ត កុំព្យូទ័រ និងអេឡិចត្រូនិច្ចជាដើម។ ឧស្សាហកម្មបែបនេះ នឹងធ្វើការផ្លាស់ប្តូរវិធីសាស្ត្របច្ចេកទេសចាស់ៗ និងអន់ថយដែលមានវត្តមាន និងកំពុងប្រើប្រាស់ក្នុងប្រទេស ទៅជាបច្ចេកវិទ្យាដ៏ទំនើប ដូចនៅក្នុងប្រទេសឧស្សាហកម្មជឿនលឿនដ៏ទៃទៀតដែរ។

ដូចនេះ ផលចំណេញដែលកម្ពុជាទទួលបានគឺបច្ចេកវិទ្យាទាន់សម័យពីក្រុមបរទេសដែលចុះមកវិនិយោគទាំងនោះ ដែលបានផ្ទេរមកឲ្យកម្មករដែលបម្រើការងារក្នុងក្រុមហ៊ុន ហើយក្រោយពីពួកគេបញ្ចប់អាជីបជាមួយក្រុមហ៊ុន ពួកគេអាចយកចំណេះដឹងដែលទទួលបាន ទៅបម្រើការឲ្យសហគ្រាសតូច ធំ នៅក្នុងស្រុកបន្តទៀត នេះជាអត្ថប្រយោជន៍ដែលកម្ពុជាទទួលបានពីក្រុមហ៊ុនវិនិយោគសម្រាប់ប្រជាជនកម្ពុជា ក៏ដូចជាសេដ្ឋកម្ពុជាផងដែរ។

ដូច្នេះហើយ ចាំបាច់ណាស់ក្រុមហ៊ុនវិនិយោគក្នុងតំបន់សេដ្ឋកិច្ច ត្រូវមានការសហប្រតិបត្តិការគ្នាទៅវិញទៅមករវាងសហគ្រាសក្នុងស្រុក និងក្រុមហ៊ុនបរទេសដោយមានការផ្លាស់ប្តូរគ្នាទៅវិញទៅមករវាងនោយោ

[38] file:///C:/Users/TSM168/Downloads/Document1282007130.1073267.pdf

ជិក ឬអ្នកគ្រប់គ្រង ឬតាមរយៈការបណ្តុះបណ្តាលនានាដែលរៀបចំឡើងដោយក្រុមហ៊ុនទាំងនោះ ក្នុងគោលដៅពង្រឹងសមត្ថភាពនិយោជិករបស់ខ្លួន។ ជាមួយគ្នានេះដែរ កម្ពុជានឹងទទួលបាននូវបច្ចេកវិទ្យាពីសហគ្រាសពហុជាតិ (Multi-National Companies) តាមរយៈការថតចំលងស្របច្បាប់ ការកែច្នៃវិស្វកម្ម (Revers Engineering) និងការវិលត្រឡប់ពីបរទេសរបស់និយោជិក ដើម្បីមកធ្វើការជាមួយក្រុមហ៊ុនក្នុងស្រុក។[39]

**Linkages between SEZs and human development**




39 file:///C:/Users/TSM168/Downloads/Document1282007130.1073267.pdf

# ជំពូកទី ៤ ៖ ការវិភាគទិន្នន័យ

## ៤.១ ការកំណត់អថេរ និងគំរូវិភាគ

គោលបំណងនៃការសិក្សានេះ គឺដើម្បីសិក្សានិងវិភាគអំពីឥទ្ធិពលនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញមកលើកំណើនសេដ្ឋកិច្ចកម្ពុជា។ ការសិក្សានេះ ធ្វើការវិភាគតាមរយៈការប្រើប្រាស់វិធីសាស្ត្រ Log-Log Regression ដែលអថេរទាំងអស់ត្រូវបានបម្លែងជាលោកនេពៃរ។

ការសិក្សានេះ ជ្រើសរើសយក FDI (Foreign direct investment), Job creation, និង Export ជាអថេរពន្យល់ និង GDP Growth Rate ជាអថេរអាស្រ័យ ដើម្បីសិក្សាពីឥទ្ធិពលនៃអថេរពន្យល់ទាំងបីមកលើ GDP Growth Rate ដែលជាអថេរអាស្រ័យ។

ដូច្នេះយើងអាចកំណត់គំរូវិភាគ(Model) បានដូចខាងក្រោម៖

$$GDP = Ae^{\alpha t}$$

$$GDP = A.FDI^{\beta_1}.JC^{\beta_2}.EX^{\beta_3}.e^{ui}$$

ដើម្បីសិក្សាពីទំនាក់ទំនងនៃអថេរ FDI, JC, និង EX ទៅលើអថេរ GDP យើងត្រូវបំលែងសមីការខាងលើទៅជាលោកនេពៃរ នោះយើងបានសមីការ Log-Linear ដូចខាងក្រោម៖

$$Ln(GDP) = LnA + \beta_1 Ln(FDI) + \beta_2 Ln(JC) + \beta_3 Ln(EX) + e$$

| | | |
|---|---|---|
| ដែល | GDP (GDP Growth Rate) | : ជាបម្រែបម្រួលកំណើន GDP គិតជាភាគរយ |
| | FDI (Foreign Direct investment) | : ជាវិនិយោគផ្ទាល់ពីបរទេសក្នុងតំបន់សេដ្ឋកិច្ចពិសេស |
| | JC (Job Creation) | : ជាការបង្កើតការងារក្នុងតំបន់សេដ្ឋកិច្ចពិសេស |
| | EX (Export) | : ជាការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេស |

## ៤.២ ការបង្ហាញទិន្នន័យ

តារាងទី ៤.១ ជាតារាងទិន្នន័យប្រើប្រាស់សម្រាប់ធ្វើការវិភាគ និងអនុវត្តគំរូវិភាគខាងលើ ដែលទិន្នន័យត្រូវបានដកស្រង់ចេញពីរបាយការណ៍របស់ក្រុមហ៊ុន និងរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មចន្លោះពេល៥ឆ្នាំគិតចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។

**តារាងទី ៤.១ ៖ ទិន្នន័យសម្រាប់ការវិភាគ**

| Year | GDP | FDI | JC | EX |
|---|---|---|---|---|
| 2015 | 2.89 | 5.90 | 9.64 | 5.60 |
| 2016 | 3.09 | 6.15 | 9.68 | 5.76 |
| 2017 | 3.10 | 6.22 | 9.75 | 5.89 |
| 2018 | 3.20 | 6.37 | 9.82 | 6.10 |
| 2019 | 3.30 | 6.50 | 9.99 | 6.25 |

**ប្រភព៖** *ក្រសួងពាណិជ្ជកម្ម និង PPSEZ (Converted into Ln by SPSS Program)*

## ៤.៣ ការបកស្រាយទិន្នន័យ

### ៤.៣.១ ការវិភាគលើលទ្ធផល

ក្នុងការបកស្រាយ និងអនុវត្តនូវសមីការ កម្មវិធី SPSS ត្រូវបានយកមកប្រើប្រាស់ដើម្បីជួយសម្រួលក្នុងការវិភាគលើលទ្ធផល។

យោងតាមតារាង ៤.២ គេអាចសរសេរសមីការបានដូចខាងក្រោម៖

$$\mathrm{GDP} = 0.158.\,\mathrm{FDI}^{0.897}.\,\mathrm{JC}^{0.092}.\,\mathrm{EX}^{-0.259}$$

(3.380) (0.028) (-0.808)

**តារាងទី ៤.២ ៖ លទ្ធផលនៃការស្រាវជ្រាវ**

| Variables | Coefficient | Std. Error | t-stat | P-value |
|---|---|---|---|---|
| Constant | -1.841 | 2.338 | -0.787 | 0.575 |
| FDI | 0.897 | 0.265 | 3.380 | 0.183 |
| JC | 0.092 | 0.329 | 0.280 | 0.826 |
| EX | -0.259 | 0.321 | -0.808 | 0.567 |

| | |
|---|---|
| R Square | .994 |
| Adjusted R Square | .997 |
| Std. Error of the Estimate | .02284 |
| F-statistics | 58.038 |

សម្គាល់៖ GDP - Independent Variable & FDI, JC,& EX - Dependent Variables

*(Calculated by SPSS Analysis Program)*

### ៤.៣.២ លទ្ធផលស្រាវជ្រាវ

**ការវិនិយោគទុនផ្ទាល់ពីបរទេសក្នុងតំបន់សេដ្ឋកិច្ចពិសេស៖** យើងឃើញថា មេគុណនៃអថេរការវិនិយោគទុនផ្ទាល់ពីបរទេសក្នុងតំបន់សេដ្ឋកិច្ចពិសេស (FDI) មានឥទ្ធិពលវិជ្ជមាន មកលើកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ តាមការវិភាគទិន្នន័យបង្ហាញក្នុងតារាងទី៤.២ អថេរការវិនិយោគទុនផ្ទាល់ពីបរទេសក្នុងតំបន់សេដ្ឋកិច្ចពិសេស (FDI) មានមេគុណ ស្មើនឹង០.៨៩៧ ដែលបង្ហាញឲ្យឃើញថា ប្រសិនបើការវិនិយោគទុនផ្ទាល់ពីបរទេសក្នុងតំបន់សេដ្ឋកិច្ចពិសេស មានការកើនឡើង ១% នោះវានឹងបណ្តាលឲ្យមានកំណើនផលិតផលក្នុងស្រុកសរុបប្រមាណ ០.៨៩៧%។

**ការបង្កើតការងារក្នុងតំបន់សេដ្ឋកិច្ចពិសេស៖** ក្នុងការវិភាគទិន្នន័យនេះ អថេរការបង្កើតការងារក្នុងតំបន់សេដ្ឋកិច្ចពិសេសមានមេគុណ (JC) ស្មើនឹង០.០៩២ មានន័យថា ការបង្កើតការងារក្នុងតំបន់សេដ្ឋកិច្ចពិសេស (JC) គឺមានន័យថាការកើនឡើងនូវការបង្កើតការងារក្នុងតំបន់សេដ្ឋកិច្ចពិសេស ១% នោះវានឹងនាំឲ្យកំណើនផលិតផលក្នុងស្រុកសរុបមានការកើនឡើង ០.០៩២%។ ទោះបីជាយ៉ាងណាក៏ដោយ គេឃើញថាការបង្កើតការងារក្នុងតំបន់សេដ្ឋកិច្ចពិសេសមិនសូវមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជាឡើយ។

**ការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេស៖** ផ្អែកតាមលទ្ធពលនៃការវិភាគទិន្នន័យលើមេគុណនៃអថេរការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេស (EX) ស្មើនឹង-០.២៥៩ បង្ហាញថា ការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេស (EX) មានឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ពោលគឺការកើនឡើងនូវការនាំចេញពីតំបន់សេដ្ឋកិច្ចពិសេស ១% នោះវានឹងនាំឲ្យកំណើនផលិតផលក្នុងស្រុកសរុបមានការធ្លាក់ចុះ ០.២៥៩%។

PPSEZ ជំរុញដល់កំណើនសេដ្ឋកិច្ច តាមរយៈការទាក់ទាញការវិនិយោគផ្ទាល់បរទេស ដែលផ្តល់ិជាលទ្ធផលនៃការបង្កើនមូលធន បរិមាណនៃកម្លាំងពលកម្មចូលទៅក្នុងប្រព័ន្ធសេដ្ឋកិច្ច ក៏ដូចជាលំហូរនៃបច្ចេកវិទ្យានិងចំណេះដឹង ដែលនេះស្របទៅនឹងទ្រឹស្តី Solow Model ដែលបានលើកឡើងថា កំណើនសេដ្ឋកិច្ចមានការចូលរួមចំណែកពីកត្តាបីសំខាន់ គឺ បច្ចេកវិជ្ជា មូលធន និងកម្លាំងពលកម្ម។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើឥទ្ធិពលនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា ដោយប្រើគំរូវិភាគក្នុងសេដ្ឋកិច្ចមាត្រសាស្ត្រ (Econometrics) យើងឃើញថា វត្តមាននៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញពិតជាចូលរួមចំណែកក្នុងការបង្កើននូវកំណើនសេដ្ឋកិច្ចជាតិពិតប្រាកដមែន។ តួយ៉ាងយើងអាចកត់សម្គាល់ឃើញថា តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ជាកាតាលីករមួយដ៏សំខាន់ក្នុងការជំរុញលើកកម្ពស់សេដ្ឋកិច្ចជាតិ ដែលឆ្លើយតបទៅនឹងការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស។ តាមរយៈការវិនិយោគផ្ទាល់ពីបរទេសមកក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនេះ បានបង្កើតការងាររហូតទៅដល់ប្រមាណ ២១៨០០ សម្រាប់ទាំងកម្មករដែលស្នាក់នៅរាជធានីភ្នំពេញនិងដែលបម្លាស់ទីមកនៅទីក្រុង។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺកម្មករដែលកំពុងធ្វើការនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ មានប្រមាណរហូតទៅដល់ ៧៣% ស្ត្រី ដែលមានន័យថា តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញបានលើកកម្ពស់និងផ្តល់ឱកាសដល់ស្ត្រីក្នុងការជួយជំរុញលើកកម្ពស់កម្រិតជីវភាពគ្រួសារឲ្យមានភាពកាន់តែប្រសើរឡើង។ ម្យ៉ាងវិញទៀត ក្នុងរូបភាពជាមីក្រូសេដ្ឋកិច្ច នៅពេលដែលចំណូលរបស់បុគ្គលម្នាក់ៗមានការកើនឡើង នោះឥរិយាបថក្នុងការប្រើប្រាស់ (Consuming Behavior) មានការប្រែប្រួលក្នុងទិសដៅវិជ្ជមាន ដែលជាលទ្ធផលនៃកំណើនសេដ្ឋកិច្ច។

សរុបមកវិញ រូបភាពទាំងអស់នេះ បានសបញ្ជាក់ពី ការចូលរួមចំណែកយ៉ាងខ្លាំងនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ក្នុងការបង្កើតការងារ និងបង្កើនចំណូល ក្នុងគោលបំណងកាត់បន្ថយក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមនៃប្រទេសកម្ពុជាឲ្យមានភាពរីកចំរើនប្រកបដោយចរភាព។ ម្យ៉ាងវិញទៀត វត្តមាននៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ជាកត្តាមួយដែលធ្វើឲ្យប្រទេសកម្ពុជាក្លាយតំបន់ទីតាំងយុទ្ធសាស្ត្រ (Strategic location) ក្នុងវិនិយោគ។

## ២. ការផ្តល់អនុសាសន៍

ជាការពិតណាស់ ក្នុងការជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលអាចធ្វើការជំរុញ តាមរយៈការបន្ថែមលើការយកចិត្តទុកដាក់ទៅលើដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រួមទាំងតំបន់សេដ្ឋកិច្ចពិសេសផ្សេងៗទៀតនៅទូទាំងព្រះរាជាណាចក្រកម្ពុជាដោយផ្តោតទៅលើ ៖

- បន្ថែមលើការលើកទឹកចិត្តវិនិយោគ (Incentive) ដល់ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសព្រោះយើងឃើញថា ក្រុមហ៊ុននៅក្រៅតំបន់សេដ្ឋកិច្ចពិសេសក៏ទទួលបាននូវការលើកទឹកចិត្តពន្ធនិងវិនិ

យោគស្រដៀងគ្នាទៅនឹងក្រុមហ៊ុនក្នុងតំបន់សេដ្ឋកិច្ចពិសេស នេះអាចធ្វើឲ្យបាត់បង់នូវប្រជាប្រិយភាពទៅលើតំបន់សេដ្ឋកិច្ចពិសេស

- ពង្រឹងគុណភាពក្នុងការផ្តល់សេវាកម្ម one window service ពីភ្នាក់ងាររដ្ឋាភិបាលដែលមាននៅតាមតំបន់សេដ្ឋកិច្ចពិសេសឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីសម្រួលដល់ដំណើរការផ្សេងៗនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស
- រៀបចំយុទ្ធសាស្ត្រនិងវិធានការណ៍ដើម្បីជួយកាត់បន្ថយនូវតម្លៃអគ្គីសនី ដោយសារតម្លៃអគ្គីសនីដែលផ្គត់ផ្គង់ដោយ EDC មានតម្លៃ ៧២០រៀលក្នុង ១KHW ស្ថិតនូវកម្រិតតម្លៃមួយដែលខ្ពស់ បើធៀបទៅនឹងតម្លៃអគ្គីសនីនៅប្រទេសជិតខាងដូចជា ប្រទេសថៃ និងប្រទេសវៀតណាម
- ធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលភ្ជាប់តំបន់សេដ្ឋកិច្ចពិសេសទៅទីផ្សារនិងច្រកព្រំដែននីមួយៗ ដើម្បីសម្រួលនិងជម្រុញដល់ការនាំចេញ ក៏ដូចជាកាត់បន្ថយថ្លៃដើមនិងបង្កើននូវផលិតភាពក្នុងការផលិត មានន័យថា នៅពេលហេដ្ឋារចនាសម្ព័ន្ធស្ថិតនូវកម្រិតមួយដែលល្អប្រសើរ នោះវានឹងធ្វើឲ្យកាត់បន្ថយពេលវេលានិងឧបសគ្គក្នុងការដឹកជញ្ជូនទាំងវត្ថុធាតុដើម (Inputs) មកកាន់រោងចក្រនិងផលិតផលសម្រេច (Outputs) ទៅកាន់ទីផ្សារ។

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

ក្រសួងពាណិជ្ជកម្ម, *របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០១៩ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២០.* https://www.moc.gov.kh/Portals/0/Docs/TradeInfo/ARរបាយការណ៍សន្និ%E2%80%8B_បាតឆ្នាំ២០១៩_Final-20191218110231285.pdf

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, សលាកប័ត្រពត៌មាន ៖ តំបន់សេដ្ឋកិច្ចពិសេស និងសិទ្ធិមនុស្សនៅកម្ពុជា, ២០១៨។ https://cchrcambodia.org/admin/media/factsheet/factsheet/khmer/20180927%20Factshhet_SEZ%20KHM%2010h13%20.pdf

គណបក្សប្រជាជនកម្ពុជា (CPP), 2020. កម្ពុជាទាក់ទាញវិនិយោគផ្ទាល់បរទេសនូវប្រាក់៣៥០០លានដុល្លារ, ចិនវិនិយោគនៅកម្ពុជាច្រើនជាងគេ. https://www.cpp.org.kh/details/175676

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា. *តំបន់សេដ្ឋកិច្ចពិសេស.* http://www.customs.gov.kh/%E1%9E%93%E1%9E%B8%E1%9E%8F%E1%9E%B7%E1%9E%9C%E1%9E%B7%E1%9E%92%E1%9E%B8%E1%9E%96%E1%9E%B7%E1%9E%9F%E1%9F%81%E1%9E%9F/%E1%9E%8F%E1%9F%86%E1%9E%94%E1%9E%93%E1%9F%8B%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85%E1%9E%96%E1%9E%B7%E1%9E%9F%E1%9F%81%E1%9E%9F-%E1%9E%8F%E1%9E%9F/


## ឯកសារជាភាសាបរទេស


Aggarwal, Aradhna. *Economic impacts of SEZs: Theoretical approaches and analysis of newly notified SEZs in India* [ឥទ្ធិពលតំបន់សេដ្ឋកិច្ចពិសេសលើសេដ្ឋកិច្ច ៖ វិធីសាស្ត្រនិងការវិភាគទ្រឹស្តីនៃតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសឥណ្ឌា]. India: Munich Personal RePEc Archive, 2010. https://mpra.ub.uni-muenchen.de/20902/2/MPRA_paper_20902.pdf

Aziz, Li, Sinclair, & Yang. *Linkages: Development Strategies, Governance and Cooperation: A Comparative Perspective of Thailand and Cambodia.* http://www.sciencespo.fr/coesionet/sites/default/files/GMS%20Final%20Report-Revise-1.pdf

DFDL. *Investment Incentives and Procedures.* https://www.dfdl.com/resources/legal-and-tax-updates/investment-guide-cambodia-investment-incentives-and-procedures/

ILO. World Employment and Social Outlook. Geneva: International Labor Organization, 2019. https://www.ilo.org/wcmsp5/groups/public/---dgreports/---dcomm/---publ/documents/publication/wcms_670542.pdf

JICA, 2010. *Study for Poverty Profiles in the Asian Region.* https://www.jica.go.jp/activities/issues/poverty/profile/pdf/cam_03_01.pdf

Jones, C, I & Vollrath, D. Introduction to Economic Growth (3rd). New York: W.W. Norton & Company, Inc, 2013.

National Bank of Cambodia. *Macroeconomic and Banking Sector Development in 2018 and Outlook for 2019*. Phnom Penh: National Bank of Cambodia, 2018. https://www.nbc.org.kh/download_files/other_reports/english/Macroeconomic_and_Banking_Sector_Development_in_2018_and_Prospects_for_2019_ENG.pdf

Peter Warr និង Jayant Menon, 2015. *Cambodia's special economic zones* [តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ]. The Philippines: Asian Development Bank. https://www.adb.org/sites/default/files/publication/175236/ewp-459.pdf

PWC, Cambodia 2018 Tax Booklet. Cambodia: PWC, 2018. https://www.pwc.com/kh/en/tax/cambodian-2018-tax-booklet1.pdf

Todaro, M, P, & Smith, S, C. *Economic development* (11th eds.) [សេដ្ឋកិច្ចអភិវឌ្ឍន៍]. (Boston: Addison-Weslay).

## ឯកសារពីគេហទំព័រ

Amadeo, Kimberly, 2020. "Economic Growth, Its Measurements, Cause, and Effects." *The balance.*https://www.thebalance.com/what-is-economic-growth-3306014

Banton, Caroline, 2020. "Neoclassical Growth Theory." *Investopedia.* https://www.investopedia.com/terms/n/neoclassical-growth-theory.asp

"Cambodia has 54 special economic zones, more to come." https://www.khmertimeskh.com/686294/cambodia-has-54-special-economic-zones-more-to-come/

CDC, *Investment Incentives*. http://www.cambodiainvestment.gov.kh/investment-scheme/investment-incentives.html

CDC, Th*e special economic zones*. Phnom Penh: The Council for the Development for Cambodia. http://www.cambodiainvestment.gov.kh/investment-scheme/the-special-economic-zones.html

CDC. *Generalized System of Preferences (GSP*). Phnom Penh: The Council for the Development for Cambodia. http://www.cambodiainvestment.gov.kh/why-invest-in-cambodia/investment-enviroment/generalized-system-of-preferences-gsp.html

Corporate Finance Institute. "What are the Different Theories of Growth?" https://corporatefinanceinstitute.com/resources/knowledge/economics/theories-of-growth/?fbclid=IwAR1e4-e6_1z9RnXYS7rm-owJXc2nEmVfSZLYfyrJrb1g11tUy7JkqTz917M

Daphne Chen, 2018. "Cambodia's low rate of unemployment doesn't tell whole story." *Phnom Penh Post.* https://www.phnompenhpost.com/national/cambodias-low-rate-unemployment-doesnt-tell-whole-story-report-finds

Dunseith, Bradley, 2017. "Import and Export Procedures in Cambodia - Best Practices." https://www.aseanbriefing.com/news/import-export-procedures-cambodia-best-practices/

Economic Online. *Structural Change Theory*. https://www.economicsonline.co.uk/Global_economics/Structural_change_theory.html

European Commission. *Everything But Arms.* https://trade.ec.europa.eu/tradehelp/everything-arms

European Commission. *Trade/Human Rights: Commission decides to partially withdraw Cambodia's preferential access to the EU market.* https://ec.europa.eu/commission/presscorner/detail/en/ip_20_229

Human and Hope Association. "Poverty." https://www.humanandhopeassociation.org/poverty/

KFA. វិស័យសំខាន់ៗ៤ដែលធ្វើឲ្យកម្ពុជាក្លាយជាកូនខ្លាសេដ្ឋកិច្ចក្នុងតំបន់. https://www.kfa.com.kh/detailnews.php?id=19

Liberto, Daniel, 2019. "Endogenous Growth Theory." *Investopedia.* https://www.investopedia.com/terms/e/endogenousgrowththeory.asp

Mom Kunthear, 2017. "Near-zero unemployment in Cambodia." *Khmer Times.* https://www.khmertimeskh.com/8543/near-zero-unemployment-in-cambodia-claims-labor-minister/

Open Development Mekong, 2019. *SEZs, Infrastructure Development, and Official Development Aid.* https://opendevelopmentmekong.net/topics/sezs-infrastructure-development-and-official-development-aid/

Pettinger, Tejvan, 2019. "Economic Growth." *Economic Help.* https://www.economicshelp.org/macroeconomics/economic-growth/

Rastogi, Vasundhara, 2018. "Cambodia's Garment Manufacturing Industry." *ASEAN Briefing.* https://www.aseanbriefing.com/news/cambodias-garment-manufacturing-industry/

Riley, Geoff. "Lewis Model of Structural Economic Growth and Development." https://www.tutor2u.net/economics/reference/lewis-model-of-structural-economic-growth-and-development

Runckel, C, W. "Cambodian Economic Zones to Fulfill Potential." http://www.business-in-asia.com/cambodia/economic_zones.html#:~:text=It%20currently%20has%20over%2077,was%20developed%20in%20three%20stages.

Santander. "Cambodia: Foreign Investment." https://santandertrade.com/en/portal/establish-overseas/cambodia/investing-3

Trading Economics. "Cambodia GDP." https://tradingeconomics.com/cambodia/gdp

Workman, Daniel, 2020. "Cambodia's Top 10 Exports." http://www.worldstopexports.com/cambodias-top-10-exports/

World Bank, 2020. *Cambodia overview* [ទិដ្ឋភាពទូទៅរបស់ប្រទេសកម្ពុជា]. Phnom Penh: World Bank. https://www.worldbank.org/en/country/cambodia/overview

World Bank. "Unemployment - Cambodia." https://data.worldbank.org/indicator/SL.UEM.TOTL.MA.ZS?locations=KH

ឈុត ប៊ុនធឿន, ២០២០. "តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទាក់ទាញការវិនិយោគខ្ពស់" https://www.khmertimeskh.com/50730389/%E1%9E%8F%E1%9E%94%E1%9E%93%E1%9E%9F%E1%9E%8A%E1%9E%8B%E1%9E%80%E1%9E%85%E1%9E%85%E1%9E%96%E1%9E%9F%E1%9E%9F%E1%9E%97-2/

សួង សុធារី, ២០១៣. "ADB៖ វិស័យសេវាកម្មបង្កើនប្រាក់ចំណូលច្រើនដល់សេដ្ឋកិច្ចកម្ពុជា." http://www.rfi.fr/km/adb-service-sector

អង្គការទិន្នន័យអំពីការអភិវឌ្ឍន៍, *វិស័យឧស្សាហកម្ម*, ២០១៥. https://opendevelopmentcambodia.net/km/topics/industries/

# ឧបសម្ព័ន្ធទី ២ ៖ ការលើកទឹកចិត្តចំពោះអ្នកវិនិយោគក្នុង PPSEZ

## Incentives for investors (1)

### Tax Incentives for Qualified Investment Project, QIP

1. Import duty exemption on construction materials and production equipment
2. Import duty exemption on production materials for export industry and export duty exemption
3. PROFIT TAX EXEMPTION




- Maximum Trigger Period: Either the first year of profit or 3 years after the QIP earns its first revenue, whichever sooner.
- Priority Period: To be determined according to the type of project and investment capital in the Financial Management Law, for light industry as below.
  - Investment Capital amount below US$5million: 0 year
  - Investment Capital amount between US$5million and US$20million: 1 year
  - Investment Capital amount more than US$20million: 2 years

## Incentives for investors (2)

### Tax Incentive for QIP-SEZ Investor

Exemption of 10% VAT in addition to import duty exemption

| Type of QIP | Construction Material | Production Equipment | Production Material |
|---|---|---|---|
| Export Industry | Exempted | Exempted | Exempted |
| Domestic Industry | Exempted | Exempted | Not Exempted |

### Other benefits

- Equal market access for foreign investors
- 50 year lease of land available to foreign investors(transferable)
- Unrestricted currency exchange and fund transfer

## ឧបសម្ព័ន្ធទី ៣ ៖ ទីតាំងភូមិសាស្ត្រ PPSEZ




## ឧបសម្ព័ន្ធទី ៤ ៖ តួលេខជាក់ស្តែងនៃ PPSEZ



## ឧបសម្ព័ន្ធទី ៥ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ

**តារាងទី១÷ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| | ២០១៨ ប. | ២០១៩ ប. | ២០២០ ព្យ. |
|---|---|---|---|
| កំណើន ផសស | ៧,៥% | ៧,១% | ៦,៥% |
| កសិកម្ម | ១,៦% | ១,៦% | ១,៧% |
| ដំណាំ | ១,៩% | ១,៧% | ១,៧% |
| ការចិញ្ចឹមសត្វ | ០,៤% | ១,៣% | ១,៤% |
| នេសាទ | ២,១% | ២,២% | ២,៤% |
| ព្រៃឈើ | -១,៤% | -១,៤% | -១,៤% |
| ឧស្សាហកម្ម | ១២,៣% | ១០,៧% | ៨,៩% |
| កាត់ដេរ | ១០,១% | ៧,១% | ៣,៥% |
| សំណង់ | ១៨,១% | ១៧,៣% | ១៦,១% |
| ឧស្សាហកម្មមិនមែនកាត់ដេរ | ១០,៣% | ១០,៥% | ១១,៥% |
| សេវាកម្ម | ៦,៥% | ៦,៧% | ៦,៤% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៥,៧% | ៥,៦% | ៥,៦% |
| លក់ដុំ-លក់រាយ | ៦,៦% | ៦,៨% | ៦,៨% |
| អចលនទ្រព្យ | ៨,៩% | ៨,៨% | ៨,៥% |
| ដឹកជញ្ជូន និងគមនាគមន៍ | ៨,១% | ៧,៩% | ៧,៧% |

ប្រភព÷ ការប៉ាន់ស្មាន និងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ មីនា ឆ្នាំ ២០១៩

## ឧបសម្ព័ន្ធទី ៦ ៖ តារាងការប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស

**តារាងទី២÷ តារាងការប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| សូចនាករ | ២០១៨ ប. | ២០១៩ ប. | ២០២០ ព្យ. |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ១៣ ០៤៨ | ១៤ ៦៨៩ | ១៥ ៦១៨ |
| ការនាំចូល ( លានដុល្លារអាមេរិក) | ១៨ ៥៩០ | ២០ ៥៥០ | ២២ ០១៨ |
| ឱនភាពគណនីចរន្ត (លានដុល្លារអាមេរិក) | ២ ៦១៥ | ២ ៥៦២ | ២ ៧២៩ |
| ការនាំចេញ (%នៃ ផសស) | ៥៣,៥ | ៥៤,៨ | ៥៣,២ |
| ការនាំចូល (%នៃ ផសស) | ៧៦,៣ | ៧៦,៧ | ៧៥,០ |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -២២,៧ | -២១,៩ | -២១,៨ |
| សមតុល្យគណនីចរន្ត (%នៃ ផសស) | -១០,៧ | -៩,៦ | -៩,៣ |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | ៣ ១១៨ | ៣ ៦៦៦ | ៤ ៣២៨ |
| វិនិយោគផ្ទាល់ពីបរទេស (កំណើនប្រចាំឆ្នាំ) | ១៦,៦ | ១៧,៦ | ១៨,១ |

ប្រភព÷ ការប៉ាន់ស្មាន និងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ មីនា ឆ្នាំ ២០១៩

ឧបសម្ព័ន្ធទី ៧ ៖ ចំនួនអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស (គិតតាមប្រទេស)




ឧបសម្ព័ន្ធទី ៨ ៖ ទំហំទឹកប្រាក់វិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស (គិតតាមប្រទេស)

